ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

លេខ: ០០៩ ១៥៧៨ អ.ជ.ប.គ.ញ


ថ្ងៃពុធ ១៤រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០

# របាយការណ៍
# ស្តីពី
# លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ត្រីមាសទី១ និងលើកទិសដៅការងារត្រីមាសទី២ ឆ្នាំ២០២០

(ថ្ងៃទី០១ ខែមករា ដល់ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០)

អនុវត្តតាមផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៥ ក៏ដូចជាគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពរបស់រាជរដ្ឋាភិបាល ពិសេសទិសដៅការងារដែលបានដាក់ចេញសម្រាប់ឆ្នាំ២០២០ដោយសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១៩ និងកិច្ចប្រជុំបូកសរុបលទ្ធផលនៃការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៤ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលមានក្រសួង ស្ថាប័ន និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ជាសមាជិក និងជាសេនាធិការ ព្រមទាំងមានការចូលរួម និងគាំទ្រពីវិស័យឯកជន វិស័យសាសនា អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ប្រជាពលរដ្ឋពីគ្រប់មជ្ឈដ្ឋានផងនោះ បានខិតខំប្រឹងប្រែងអនុវត្តការងារក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីរួមចំណែកថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការអភិវឌ្ឍសង្គម និងកសាងធនធានមនុស្សប្រកបដោយសក្តានុពលភាពសម្រាប់ជាតិ ហើយទទួលបានលទ្ធផលគួរជាទីមោទនៈ ដូចខាងក្រោម ៖

## I. សភាពការណ៍គ្រឿងញៀន

### ក. សភាពការណ៍គ្រឿងញៀនអន្តរជាតិ និងតំបន់ [1] ៖

ក្នុងត្រីមាសទី១ ដើមឆ្នាំ២០២០ នេះ តាមរយៈកិច្ចប្រជុំ ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់គ្រឿងញៀន (ADEC-25)លើកទី២៥ នៅប្រទេសជប៉ុនកន្លងទៅ និងកិច្ចប្រជុំអន្តរជាតិនានា ស្តីពីគ្រឿងញៀន នៅតែបង្ហាញឲ្យឃើញថា តម្រូវការគ្រឿងញៀនសំយោគនៅតែមានកំណើនខ្ពស់ទាំងក្នុងកម្រិតតំបន់ និងពិភពលោក ពិសេសទីផ្សារគ្រឿងញៀនប្រភេទមេតំហ្វេតាមីនក្រាមម្សៅមានការកើនឡើងខ្លាំង ក្នុងពេលដែលដំណាំអាភៀន ក៏ដូចជាគ្រឿងញៀនប្រភេទហេរ៉ូអ៊ីនមានការថយចុះនៅក្នុងតំបន់ទាំងមូល។ ជាមួយគ្នានេះ សកម្មភាពនៃការផលិតគ្រឿងញៀននៅក្នុងតំបន់ ភាគច្រើនប្រព្រឹត្តដោយក្រុមឧក្រិដ្ឋជនប្រដាប់ដោយអាវុធដែលទទួលមូលនិធិពីក្រុមឧក្រិដ្ឋជនគ្រឿងញៀនអន្តរជាតិ និងបានពង្រីកខ្លួនកាន់តែធំជាងមុន ។ ដោយឡែក ការផលិតអាភៀនមួយចំនួនបានផ្លាស់ប្តូរទៅផលិតគ្រឿងញៀនសំយោគ ធ្វើឱ្យបរិមាណគ្រឿងញៀនសំយោគដែលបង្ក្រាបបានមានការកើនឡើងខ្លាំង ភាពសុទ្ធនៃគ្រឿងញៀនប្រភេទនេះ(ពិសេសមេតំហ្វេតាមីនក្រាមម្សៅ)មានកម្រិតកាន់តែខ្ពស់ ធ្វើឲ្យតម្លៃគ្រឿងញៀនសំយោគ

[1] សភាពការណ៍គ្រឿងញៀនអន្តរជាតិ និងក្នុងតំបន់ ដកស្រង់ពីរបាយការណ៍កិច្ចប្រជុំ ADEC-25




អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ មានទីតាំងនៅក្នុងបរិវេណក្រសួងមហាផ្ទៃ, Phone, Fax: (855) 23 721 648, Fax: (855) 23 727 529 P.O.Box: 151
E-mail: info@nacd.gov.kh Website : www.nacd.gov.kh

ធ្លាក់ចុះថោក ដែលរុញឲ្យទីផ្សារគ្រឿងញៀនប្រភេទនេះកាន់តែរីកធំនៅក្នុងតំបន់។ជាមួយគ្នានេះ ក៏បានពិនិត្យឃើញថា ភូមិសាស្ត្រក្នុងដែនសមុទ្រនៅតែជាផ្លូវដ៏សំខាន់ក្នុងការចរាចរគ្រឿងញៀន ទាំងក្នុងតំបន់ និងពិភពលោក ។

ជាមួយនឹងការកត់សម្គាល់ឃើញ មានការកើនឡើងខ្លាំងនូវការចរាចរគ្រឿងញៀនមេតំហ្វេតាមីនចេញពីតំបន់ត្រីកោណមាសឆ្លងកាត់បណ្តាប្រទេសក្នុងមហាអនុតំបន់ទន្លេមេគង្គទៅកាន់ប្រទេសដែលមានតម្រូវការ និងទីផ្សារប្រើប្រាស់គ្រឿងញៀនខ្ពស់ និងការលួចនាំចូលសារធាតុគីមីផ្សំគ្រឿងញៀនទៅកាន់តំបន់នោះក្នុងចំនួនដ៏ច្រើនលើសលប់ដោយមិនមានការត្រួតពិនិត្យឲ្យបានជិតដល់ ហើយដើម្បីឆ្លើយតបទៅនឹងសភាពការណ៍ដូចនេះ កាលពីឆ្នាំ២០១៩ កន្លងទៅនេះ កម្ពុជាបានទទួលធ្វើជាម្ចាស់ផ្ទះរៀបចំមជ្ឈមណ្ឌលសម្របសម្រួលសុវត្ថិភាពទន្លេមេគង្គ(Safe Mekong Coordination Centre) ដែលមានមន្ត្រីសម្របសម្រួលប្រចាំការមកពីបណ្តាប្រទេសសមាជិក SMCC ទាំង៦ គឺ កម្ពុជា ថៃ ឡាវ ចិន វៀតណាម និងមីយ៉ាន់ម៉ា និងនៅក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីនៃបណ្តាប្រទេសជាសមាជិកMOUនៅប្រទេសថៃ កន្លងទៅ ប្រទេសទាំង០៦ក្នុងមហាអនុតំបន់ទន្លេមេគង្គ បានឯកភាពគ្នាដាក់ចេញនូវប្រតិបត្តិការ១៥១១ ដើម្បីបង្កើនប្រសិទ្ធភាពអនុវត្តច្បាប់ ក៏ដូចជាការដាក់សម្ពាធលើក្រុមឧក្រិដ្ឋជន សំដៅបង្ការ ទប់ស្កាត់ បង្ក្រាបការផលិត និងចរាចរគ្រឿងញៀនចេញពីតំបន់ត្រីកោណមាស និងការចរាចរសារធាតុគីមីផ្សំចូលក្នុងតំបន់នេះ ។

### ខ. សភាពការណ៍គ្រឿងញៀនកម្ពុជា :

ដោយសារនិន្នាការផលិត ចរាចរ ជួញដូរគ្រឿងញៀនលើពិភពលោក និងក្នុងតំបន់ នៅតែមានស្ថានភាពប្រែប្រួលកើនឡើងឥតឈប់ឈរ ហើយល្បិចកលលួចលាក់ធ្វើសកម្មភាពរបស់ក្រុមឧក្រិដ្ឋជនកាន់តែស្មុគស្មាញ ដូចបានរៀបរាប់ខាងលើ ធ្វើឲ្យកម្ពុជានៅតែបន្តទទួលរងនូវឥទ្ធិពលដ៏អាក្រក់ និងការគំរាមកំហែងពីការចរាចរឆ្លងកាត់ និងហូរចូលគ្រឿងញៀន ទាំងតាមផ្លូវគោក ផ្លូវទឹក ផ្លូវអាកាស និងតាមបញ្ញើប្រៃសណីយ៍ ក៏ដូចជាការប៉ុនប៉ងផលិតកែច្នៃគ្រឿងញៀន និងការរីករាលដាលនៃការប្រើប្រាស់គ្រឿងញៀននៅផ្ទៃក្នុងប្រទេស ។ ជាក់ស្តែងក្នុងត្រីមាសទី១ ឆ្នាំ២០២០នេះ ការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៥(ពីថ្ងៃទី០១ខែមករាដល់ថ្ងៃទី៣១ខែមីនាឆ្នាំ២០២០)របស់រាជរដ្ឋាភិបាល ត្រូវបានចាត់តាំងអនុវត្តយ៉ាងសកម្មនូវវិធានការគន្លឹះទាំង៥ ដែលរួមមាន៖ វិធានការអនុវត្តច្បាប់ យើងបង្ក្រាបបាន **២.៦៦០ ករណី** ឃាត់ខ្លួនជនសង្ស័យ **៥.៣១៣ នាក់** រឹបអូសគ្រឿងញៀនបានជាង **១០១គីឡូក្រាម** , វិធានការអប់រំផ្សព្វផ្សាយ ដោយបានគ្របដណ្តប់ទៅលើអ្នកមកទទួលយកសារអប់រំចំនួនជាង **១លាន ៨សែន នាក់** , វិធានការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន យើងគ្រប់គ្រងបានអ្នកប្រើប្រាស់ និងអ្នកញៀនគ្រឿងញៀន**ចំនួន ៨.៤៧៥ នាក់**។ វិធានការរដ្ឋបាល យើងអនុវត្តបានចំនួន **៤០២ លើក លើ០៥គោលដៅ** និងបានធ្វើតេស្តរកសារធាតុញៀនលើមុខសញ្ញាមួយចំនួនធំ។បានចូលរួមសហការសម្របសម្រួលអនុវត្តក្នុងភាពជាដៃគូនៃកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន តាមរយៈជំនួបពិភាក្សាការងារ ចូលរួមកិច្ចប្រជុំ វគ្គបណ្តុះបណ្តាល សិក្ខាសាលា ទាំងក្នុងក្របខណ្ឌ អនុតំបន់ តំបន់ និងអន្តរជាតិ ។

## I. អំពីការងារដឹកនាំ

ក្នុងគោលបំណងបង្ការ ទប់ស្កាត់ បង្ក្រាប និងដោះស្រាយ ឱ្យកាន់តែមានប្រសិទ្ធភាពនូវរាល់បញ្ហាដែលមានការពាក់ព័ន្ធនឹងគ្រឿងញៀន ក៏ដើម្បីរក្សាបាននូវសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការអភិវឌ្ឍន៍សង្គម និងផ្តល់សុខុមាលភាពជូនប្រជាពលរដ្ឋ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក៏ដូចរាជរដ្ឋាភិបាលទាំងមូល បានយកចិត្តទុកដាក់ដឹកនាំ សម្របសម្រួល និងអនុវត្តប្រកបដោយការទទួលខុសត្រូវខ្ពស់នូវផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៥ គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព និងវិធានការចាំបាច់នានា ក៏ដូចជាការងារពាក់ព័ន្ធសំខាន់ៗផ្សេងទៀត ជាអាទិ៍ ៖

## ១. ការដឹកនាំរបស់ស្ថាប័នកំពូលថ្នាក់ជាតិ

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានបន្តយកចិត្តទុកដាក់ណែនាំ និងចង្អុលបង្ហាញលើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ដោយបាន ៖

- ជួបសំណេះសំណាល និងបញ្ជ្រាបបញ្ហាគ្រឿងញៀន ដើម្បីជាការដាស់តឿនក្រើនរំលឹកដល់កម្មករ កម្មការិនី នៅតាមរោងចក្រ សហគ្រាសនានានៅទូទាំងប្រទេស

- ប្រគល់ភារកិច្ចជូន **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** និង **ឯកឧត្តម កែ គឹមយ៉ាន ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ.** ក្នុងនាមរាជរដ្ឋាភិបាលឲ្យបន្តការដឹកនាំអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៥ ដោយប្រមូលផ្តុំសមាសភាពពីគ្រប់មជ្ឈដ្ឋានសង្គម អនុវត្តនូវវិធានការសរុប ប្រើប្រាស់កម្លាំងសរុប មធ្យោបាយសរុប ក្នុងការពង្រឹងយន្តការដែលមានស្រាប់ និងរៀបចំយន្តការចាំបាច់បន្ថែម ក៏ដូចជាកសាងផែនការសកម្មភាពមួយចំនួនទៀត ដើម្បីឲ្យការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៥ មានប្រសិទ្ធភាព មានការទទួលខុសត្រូវ និងកាន់តែទទួលបាននូវការចូលរួមគាំទ្រពីគ្រប់មជ្ឈដ្ឋានជាតិ និងអន្តរជាតិ

- នាឱកាសអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបិទសន្និបាតបូកសរុបការងារឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ របស់ក្រសួងមហាផ្ទៃ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានអំពាវនាវឲ្យបង្កើនការទប់ស្កាត់ និងដោះស្រាយបញ្ហាគ្រឿងញៀន តាមរយៈការចុះធ្វើវេទិកាសាធារណៈឲ្យបានទូលំទូលាយ ស្របតាមគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពរបស់រាជរដ្ឋាភិបាល ។

**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា** ក្នុងឱកាសអញ្ជើញចុះជួបសំណេះសំណាលសួរសុខទុក្ខ និងផ្តល់អំណោយមនុស្សធម៌កាកបាទក្រហម ដល់ប្រជាពលរដ្ឋដែលជួបប្រទះគ្រោះធម្មជាតិ និងនៅតាមវេទិកាមនុស្សធម៌នានា បានអំពាវនាវដល់គ្រប់សមត្ថកិច្ចអនុវត្តច្បាប់ ឲ្យខិតខំប្រើប្រាស់វិធានការជំនាញក្នុងការលុបបំបាត់ការជួញដូរ និងប្រើប្រាស់គ្រឿងញៀន ដើម្បីចូលរួមអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាពរបស់រាជរដ្ឋាភិបាល ឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ក៏ដូចជាបានអំពាវនាវដល់ប្រជាពលរដ្ឋទូទៅក្នុងសហគមន៍ ចូលរួមឲ្យបានសកម្មជាមួយអាជ្ញាធរដែនដី និងរាជរដ្ឋាភិបាល ដើម្បីទប់ស្កាត់ និងដោះស្រាយបញ្ហាគ្រឿងញៀននៅក្នុងមូលដ្ឋានរបស់ខ្លួន ។

**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** បានផ្តល់អនុសាសន៍ដឹកនាំឲ្យបន្តពង្រឹងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព គោលនយោបាយភូមិ-ឃុំសង្កាត់ ស គ្មានគ្រឿងញៀន និងបទបញ្ជាលេខ ០១ ស្តីពីការពង្រឹងវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀនរបស់រាជរដ្ឋាភិបាល។ បន្តពង្រឹងការអនុវត្តវិធានការរដ្ឋបាល និងចាត់វិធានការបង្ក្រាបនៅតាមក្លឹបកម្សាន្ត និងទីតាំងសប្បាយដ្ឋាន ដែលពាក់ព័ន្ធនឹងគ្រឿងញៀន ។ បន្តស្រាវជ្រាវ បង្ក្រាបករណីផលិតកែច្នៃគ្រឿងញៀន និងករណីដាំដុះដំណាំកញ្ឆា។ ជាមួយគ្នានេះក៏បានធ្វើការអំពាវនាវឲ្យគ្រប់វេទិកាសំណេះសំណាល ក្នុងពិធីបុណ្យឆ្លងសមិទ្ធផលនានា ឲ្យគ្រប់មជ្ឈដ្ឋានសង្គម និងកំលាំងអនុវត្តច្បាប់ទាំងអស់ អនុវត្តនូវទិសស្លោក ៣កុំ ១រាយការណ៍ គឺ៖ ១-កុំឲ្យពាក់ព័ន្ធ ២-កុំអន្តរាគមន៍ ៣-កុំលើកលែង និងត្រូវរាយការណ៍គ្រប់ករណីបទល្មើសគ្រឿងញៀន ។ ព្រមទាំងស្នើឲ្យពន្លឿនដំណើរការបង្កក ដំរុញនីតិវិធីរឹបអូស និងលក់ទ្រព្យដែលពាក់ព័ន្ធបទល្មើសគ្រឿងញៀន ដើម្បីឲ្យការប្រមូលមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ឆ្លើយតបបានទៅនឹងតម្រូវការជាក់ស្តែងនៃដំណោះស្រាយគ្រឿងញៀននៅកម្ពុជា ។

## ២. ការដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

ក្នុងនាមអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន ប្រធាន អ.ជ.ប.គ.ញ.** បានណែនាំនូវគោលការណ៍សំខាន់ៗ ដែលបានដាក់ចេញក្នុងសន្និបាតបូកសរុបលទ្ធផលការងារត្រួត

ពិនិត្យគ្រឿងញៀន ឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ និងកិច្ចប្រជុំបូកសរុបលទ្ធផលអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៤ កាលពីថ្ងៃទី១៦-១៧ ខែមីនា ឆ្នាំ២០១៩ ក្នុងនោះរួមមានៈ ការងារអប់រំផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន,ការងារព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន , ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តច្បាប់ , ការត្រួតពិនិត្យសារជាតុគីមីផ្សំ , កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន ប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍ , ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ , ការពង្រឹងការអនុវត្តស្មារតីអនុក្រឹត្យស្តីពីមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ស្របតាមផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន ផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៥ និងទិសដៅការងារសម្រាប់ត្រីមាសទី២ ឆ្នាំ២០២០។ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ. ក៏បានណែនាំ និងអំពាវនាវឱ្យមន្ត្រីរាជការ ប្រជាពលរដ្ឋ ចូលរួមបង្ការ ទប់ស្កាត់មេរោគរាតត្បាតកូវីដ-១៩(COVID-19)នៅប្រទេសកម្ពុជា។

ក្រៅពីការណែនាំខាងលើ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ.** បានៈ

- អញ្ជើញជាអធិបតីនៅក្នុងវេទិកាសំណេះសំណាល ក៏ដូចជានៅក្នុងពិធីបុណ្យឆ្លងសមិទ្ធផលនានា ដោយបានធ្វើការបញ្ជ្រាបខ្លឹមសារអប់រំអំពីគ្រោះថ្នាក់នៃគ្រឿងញៀន ដល់មន្ត្រីរាជការ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ប្រជាពលរដ្ឋ អាជ្ញាធរដែនដី និងកងកម្លាំងប្រដាប់អាវុធ នៅក្រុងសិរីសោភ័ណ ស្រុកភ្នំស្រុក ស្រុកថ្មពួក ស្រុកមង្គលបូរី និងស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ដែលមានអ្នកចូលរួមប្រមាណជា **២ ម៉ឺន**នាក់ ។
- អនុញ្ញាតឲ្យឯកអគ្គរដ្ឋទូត សហរដ្ឋអាមេរិក ចូលជួបសំដែងការគួរសម និងពិភាក្សាការងារពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀននៃប្រទេសទាំងពីរ
- អញ្ជើញចូលរួមក្នុងពិធីបិទសន្និបាតត្រួតពិនិត្យការងារឆ្នាំ២០១៩ និងលើកទិសដៅឆ្នាំ២០២០របស់ក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ
- អញ្ជើញចូលរួមក្នុងពិធីបិទសន្និបាតបូកសរុបការងារសុខាភិបាលប្រចាំឆ្នាំ២០១៩ លើកទី៤១ **សម្តេចអគ្គមហាសេនាបតេតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាតក្រហមកម្ពុជា** នៅសណ្ឋាគាររ៉េស៊ីដង់សុខាភ្នំពេញ
- ដឹកនាំអង្គសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ និងកិច្ចប្រជុំបូកសរុបលទ្ធផលអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៤ កាលពីថ្ងៃទី១៦ ដល់ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ នៅទីស្តីការក្រសួងមហាផ្ទៃ ។

ក្រៅពីសកម្មភាពពាក់ព័ន្ធនឹងការងារត្រួតពិនិត្យគ្រឿងញៀន **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ.** ក៏បាន ៖

- អញ្ជើញចូលរួមក្នុងពិធីអបអរសាទរខួបលើកទី១០៩ ទិវាអន្តរជាតិ៨មីនា ឆ្នាំ២០២០ ក្រោមប្រធានបទ ″ មានសន្តិភាព មានការលើកកម្ពស់សមភាពយេនឌ័រ ″ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាតក្រហមកម្ពុជា** នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ
- អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងកិច្ចប្រជុំផ្សព្វផ្សាយស្មារតីសន្និបាតគណៈកម្មការកណ្តាលគណបក្សប្រជាជនកម្ពុជាលើកទី៤២ អាណត្តិទី៥ កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២០ នៅខេត្តបន្ទាយមានជ័យ

- អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីប្រគល់ផ្ទះចំនួន១២៩ខ្នងផ្ទះ ដល់គ្រួសារអតីតយុទ្ធជន ក្នុងពិធីសម្ពោធឆ្លងសមិទ្ធិផលនានា ក្នុងពិធីចុះជួបសំណេះសំណាល សួរសុខទុក្ខ និងផ្តល់អំណោយមនុស្សធម៌ដល់ប្រជាពលរដ្ឋដែលជួបប្រទះគ្រោះធម្មជាតិ នៅទូទាំងខេត្តបន្ទាយមានជ័យ ។

- អញ្ជើញជាអធិបតីក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារ ឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ របស់រដ្ឋបាលខេត្តបន្ទាយមានជ័យ។

- អញ្ជើញចូលរួមក្នុងពិធីបើកការដ្ឋានឡើងវិញកំណាត់ផ្លូវជាតិលេខ២ និងផ្លូវជាតិលេខ២២ ចាប់ពីរង្វង់មូលតាខ្មៅ អូរចំបក់ និងទៅដល់អង្គតាសោម ក្រោមហិរញ្ញប្បទានពីរដ្ឋាភិបាល នៃសាធារណៈរដ្ឋកូរ៉េ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាតក្រហមកម្ពុជា

- អញ្ជើញចូលរួមក្នុងពិធីសម្ពោធបើកឱ្យប្រើប្រាស់ជាផ្លូវការលេខ៥៨ ពីប៉ោយប៉ែត ផ្លូវជាតិលេខ៥ ដល់ផ្ទុង ផ្លូវជាតិលេខ៦៨ ប្រវែង១៧៤.១៦ម៉ែត្រ នៅភូមិផ្សារកណ្តាល សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាតក្រហមកម្ពុជា**

- រៀបចំពិធីបុណ្យផ្កាប្រាក់មូលនិធិជួសជុលប្រាសាទបន្ទាយឆ្មារ ដើម្បីជួសជុលប្រាសាទបន្ទាយឆ្មារ ខេត្តបន្ទាយមានជ័យ

- អញ្ជើញចូលរួមអមដំណើរ ក្នុងពិធីសម្ពោធបើកឱ្យប្រើប្រាស់ជាផ្លូវការនូវផ្លូវជាតិលេខ៥៥ ប្រវែងសរុប ១៨២,១៦គ.ម ខេត្តពោធិ៍សាត់ ចាប់ពីផ្លូវជាតិលេខ៥ (គ.ម១៩១) ទៅវាលវែង-ថ្មដា (ព្រំដែនកម្ពុជា-ថៃ) និងបើកការដ្ឋានសាងសង់ផ្លូវជាតិលេខ១០ ពីសំឡូត បាត់ដំបង-វាងវែង ខេត្តពោធិ៍សាត់ ទៅដល់ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ប្រវែងសរុប ១៩៨,៧១គ.ម ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

- អញ្ជើញចូលរួមកិច្ចប្រជុំវិសាមញ្ញរដ្ឋសភានីតិកាលទី៦ ដើម្បីពិនិត្យសេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី១ ធ្វើវិសោធនកម្មសេចក្តីព្រាងស្តីពីពាណិជ្ជកម្ម ទំនិញអាស៊ាន នៅសាលប្រជុំរដ្ឋសភា

- អញ្ជើញចូលរួមសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញនីតិកាលទី៦ ស្តីពីការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តលើការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល។

**ជាមួយគ្នានេះ**ឯកឧត្តម នាយឧត្តមសេនីយ៍ **ជួន សុវណ្ណ** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រៅពីទទួលជួយលើការងារដឹកនាំរួមអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំ និងកម្មវិធីនានាពាក់ព័ន្ធនឹងការងារត្រួតពិនិត្យគ្រឿងញៀន ដូចជា៖ ដឹកនាំកិច្ចប្រជុំត្រួតពិនិត្យការងារប្រចាំខែរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ,ដឹកនាំកិច្ចប្រជុំក្រុមការងារអន្តរក្រសួងរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងរបាយការណ៍ ស្តីពីលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ , ដឹកនាំកិច្ចប្រជុំគណៈកម្មការសាងសង់មជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ ដល់អ្នកញៀនគ្រឿងញៀននៅខេត្តព្រះសីហនុ , ចូលរួមកិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច-ហិរញ្ញវត្ថុ ដែលរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអញ្ជើញជាអធិបតីក្នុងសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១៩ លើកទិសដៅការងារឆ្នាំ២០២០ និងកិច្ចប្រជុំបូកសរុបលទ្ធផលអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៤ កាលពីថ្ងៃទី១៦ ដល់ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ នៅទីស្តីការក្រសួងមហាផ្ទៃ ។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

ក្នុងត្រីមាសទី១ ដើមឆ្នាំ២០២០ នេះ យោងតាមផែនការជាតិ ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ក៏ដូចជាផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៥ និងទិសដៅការងារដែលបានដាក់ចេញសម្រាប់ឆ្នាំ២០២០ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រួមទាំងក្រសួង-ស្ថាប័ន សមាជិក និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត បានខិតខំបន្តសម្របសម្រួល និងអនុវត្តការងារដោយទទួលបានលទ្ធផល ដូចខាងក្រោម ៖

### ១. ការអប់រំផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

អនុវត្តតាមគោលការណ៍ដឹកនាំ ឲ្យបង្កើនការអប់រំផ្សព្វផ្សាយឲ្យបានដល់គោលដៅប្រឈមខ្ពស់ ពង្រឹងគុណភាពឯកសារអប់រំឲ្យស្របទៅនឹងចិត្តសាស្ត្រមុខសញ្ញាដែលងាយរងគ្រោះ បន្តចាត់តាំង ចងក្រង និងបណ្តុះបណ្តាលជនបង្គោលនៅគ្រប់ក្រសួង ស្ថាប័ន អង្គភាព ដើម្បីធ្វើសកម្មភាពអប់រំផ្សព្វផ្សាយឲ្យបានសកម្មផុលផុសជាប្រចាំ និងគ្រប់ទីកន្លែង។ បន្តផ្សព្វផ្សាយទិសស្លោករបស់**សម្តេចក្រឡាហោម ស ខេង** ៣កុំ ១រាយការណ៍ គឺៈ ១-កុំពាក់ព័ន្ធ ២-កុំអន្តរាគមន៍ ៣-កុំលើកលែង និងត្រូវរាយការណ៍គ្រប់ករណីបទល្មើសគ្រឿងញៀន ទៅគ្រប់វេទិកា និងព្រឹត្តការណ៍ផ្សេងៗក្នុងភូមិសាស្ត្រនៃដែនសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន អង្គភាព និងរាជធានី ខេត្ត ។ បន្តដាក់សារហាមឃាត់ការជួញដូរ និងប្រើប្រាស់គ្រឿងញៀន នៅក្នុងបទបញ្ជាផ្ទៃក្នុងសណ្ឋាគារ ផ្ទះសំណាក់។ល។ និងនៅគ្រប់ផលិតផល ។ បន្តបើកវគ្គបណ្តុះបណ្តាលអំពីចំណេះដឹងជាមូលដ្ឋាននៃគ្រឿងញៀន និងច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀនដល់មូលដ្ឋានឃុំ-សង្កាត់ និងបន្តសហការជាមួយក្រសួង អប់រំ យុវជន និងកីឡា ដើម្បីរៀបចំបណ្ណាល័យឌីជីថលអប់រំផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀន ស្របតាមគោលនយោបាយជាតិស្តីពីសុខភាពសិក្សា នៅតាមគ្រឹះស្ថានសិក្សាសាធារណៈ។ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រួមជាមួយក្រសួង ស្ថាប័ន សមាជិក និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត បានអនុវត្តការងារដោយទទួលបាននូវលទ្ធផល ៖

#### ១.១ ការអប់រំតាមប្រព័ន្ធផ្សព្វផ្សាយ ៖

– ក្រសួង ស្ថាប័ន អង្គភាព ជាសមាជិក អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត បានចូលរួមផ្តល់បទសម្ភាសន៍ពាក់ព័ន្ធនឹងបញ្ហាគ្រឿងញៀនតាមប្រព័ន្ធផ្សព្វផ្សាយ ដូចជា វិទ្យុទូរទស្សន៍រដ្ឋ និងឯកជន

– បានបញ្ចូលខ្លឹមសារអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន ទៅក្នុងផលិតផលភាពយន្ត បណ្តាញទូរស័ព្ទចល័ត បណ្តាញព័ត៌មានអេឡិកត្រូនិច តាមសៀវភៅព្រឹត្តិប័ត្រ និងផ្សព្វផ្សាយជាឃ្លីបវីដេអូខ្លីស្តីពីគ្រឿងញៀននៅតាមគេហទំព័រ ក៏ដូចជាក្នុង Page Facebook ជាដើម។ល។ ក្នុងនោះមាន ៖

- តាមរយៈគេហទំព័រ អ.ជ.ប.គ.ញ.(www.nacd.gov.kh)មានអ្នកចូលអានសរុប **៤១.៨១៥ ដង**
- តាមរយៈសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ បានបញ្ចូលសារអប់រំអំពីគ្រឿងញៀន"គ្រឿងញៀនបង្ករឲ្យមានអំពើហឹង្សា និងឧក្រិដ្ឋកម្ម"ទៅក្នុងផលិតផលភាពយន្តទាំងខ្មែរ បរទេស និងបណ្តាក្រុមហ៊ុនផលិតកម្មនានា បានចំនួន **១៨៤.៤៤២ ឌីស** ស្មើនឹងអ្នកដែលបានទទួលសារអប់រំពីគ្រឿងញៀន តាមរយៈសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ ចំនួន **៣៦៨.០៨៤** ដង នាក់ ។

#### ១.២ កម្មវិធីអប់រំផ្សព្វផ្សាយតាមសហគមន៍ ៖

ការងារអប់រំផ្សព្វផ្សាយអំពីបញ្ហាគ្រឿងញៀននៅតាមសហគមន៍ មានដូចជា ក្នុងព្រះរាជពិធី និងពិធីបុណ្យប្រពៃណីជាតិ កម្មវិធីព្រះពុទ្ធសាសនាផ្សារភ្ជាប់នឹងសង្គម វេទិកាសាធារណៈ កម្មវិធីសំណេះសំណាលក្នុងវេទិកាមនុស្សធម៌ ពិធីបុណ្យឆ្លងសមិទ្ធផលនានា និងព្រឹត្តិការណ៍សង្គមផ្សេងៗទៀត។ល។ នៅតាមទីសាធារណៈ វត្តអារាម គ្រឹះស្ថានសិក្សា រោងចក្រ សហគ្រាស និងការចុះចែកចាយខិត្តប័ណ្ណពាក់ព័ន្ធនឹងការបង្ការ ទប់ស្កាត់ការចរាចរ ជួញដូរ រក្សាទុក ប្រើប្រាស់គ្រឿងញៀន និងការផ្សព្វផ្សាយអំពីទីតាំងមូលដ្ឋានសុខាភិបាលសាធារណៈដែលដាក់ឲ្យបម្រើសេវា

ព្យាបាលសុខភាពផ្លូវចិត្ត និងភាពញៀនគ្រឿងញៀន ។ សម្រាប់ត្រីមាសទី១ ដើមឆ្នាំ២០២០នេះ រាជរដ្ឋាភិបាល អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រសួង ស្ថាប័ន សមាជិក និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី ខេត្ត បានសម្របសម្រួល និងអនុវត្តការងារដោយទទួលបាននូវលទ្ធផលដូចខាងក្រោម៖

**១.២.១.** បុគ្គលិក កម្មករ កម្មការិនីប្រមាណ **១ម៉ឺន** នាក់ បានទទួលសារអប់រំអំពីគ្រោះថ្នាក់នៃគ្រឿងញៀនពី **សម្តេចតេជោនាយករដ្ឋមន្ត្រី** ក្នុងពិធីជួបសំណេះសំណាលនៅតាមបណ្តារោងចក្រ ។

**១.២.២.** ទទួលបានការណែនាំ និងចង្អុលបង្ហាញពី**សម្តេចកិត្តិព្រឹទ្ធបណ្ឌិតប៊ុនរ៉ានី ហ៊ុន សែន** ក្នុងឱកាសចុះជួបសំណេះសំណាលសួរសុខទុក្ខ និងផ្តល់អំណោយមនុស្សធម៌កាកបាទក្រហមរបស់ថ្នាក់ដឹកនាំ និងសាខាកាកបាទក្រហមរាជធានី ខេត្ត បានផ្តល់សារអប់រំអំពីបញ្ហាគ្រឿងញៀន ជូនប្រជាពលរដ្ឋប្រមាណ **១ម៉ឺន** នាក់ នៅតាមវេទិកាមនុស្សធម៌នានា ។

**១.២.៣.** មន្ត្រីរាជការ អាជ្ញាធរដែនដី កងកម្លាំងប្រដាប់អាវុធ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ប្រជាពលរដ្ឋប្រមាណ **២ម៉ឺន** នាក់ បានទទួលសារអប់រំអំពីបញ្ហាគ្រឿងញៀនពី **សម្តេចក្រឡាហោម ស ខេង** នាឱកាសសម្តេចអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំ ពិធីជួបសំណេះសំណាលក្នុងវេទិកាសាធារណៈ ក៏ដូចជាក្នុងពិធីបុណ្យឆ្លងសមិទ្ធផលនានា នៅតាមរាជធានី ខេត្តមួយចំនួន ។

**១.២.៤.** មន្ត្រីរាជការ អាជ្ញាធរដែនដី កងកម្លាំងប្រដាប់អាវុធ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋប្រមាណ **២ម៉ឺន** នាក់ បានទទួលសារអប់រំអំពីបញ្ហាគ្រឿងញៀនពី **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន** នាឱកាសឯកឧត្តមអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំ ពិធីជួបសំណេះសំណាលនៅតាមវេទិកាសាធារណៈ និងក្នុងពិធីបុណ្យឆ្លងសមិទ្ធផលនានា ។

**១.២.៥.** ក្រសួងសមាជិក អ.ជ.ប.គ.ញ.រួមមាន ៖ ក្រសួងមហាផ្ទៃ ក្រសួងអប់រំ យុវជន និងកីឡា , ក្រសួងកិច្ចការនារី, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ,ក្រសួងសាធារណការ និងដឹកជញ្ជូន , ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ , ក្រសួងការពារជាតិ , ក្រសួងយុត្តិធម៌ និងក្រសួងទេសចរណ៍ បានធ្វើការអប់រំផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀន នៅក្នុងវិស័យជំនាញរបស់ខ្លួន ដោយគ្របដណ្តប់លើអ្នកមកទទួលសារអប់រំចំនួន **៨៨៧.៦៩៣ នាក់** ។

**(សកម្មភាពអប់រំផ្សព្វផ្សាយផ្សេងទៀតរបស់ក្រសួង ស្ថាប័ន អង្គភាព មានលម្អិតនៅក្នុងតារាងឧបសម្ព័ន្ធ)**

**១.២.៦.** គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ធ្វើការអប់រំផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀន បានចំនួន **២៦.៩៨៦** លើក ដោយគ្របដណ្តប់លើអ្នកមកទទួលយកសារអប់រំ **១.២២៧.៨១០** នាក់/ស្រី **៦១២.៦១៨** នាក់ ក្នុងនោះ ៖ តាមគ្រឹះស្ថានសិក្សា **១.៨៣៣** លើក អ្នកចូលរួម **២៣៩.២១៧** នាក់/ស្រី **១២៦.៣៨០** នាក់ , តាមវេទិកាសាធារណៈ **១៩.៣៧៥** លើក អ្នកចូលរួម **៩៣៦.៩៤៥** នាក់/ស្រី **៤៦០.៩១៣** នាក់ , តាមរយៈវិស័យសាសនា **២៤៧** លើក អ្នកចូលរួម **៤៨.៦៣០** នាក់/ស្រី **២៤.៨១៥**នាក់ , តាមរយៈប្រព័ន្ធផ្សព្វផ្សាយ **៤.៨៦២**លើក និងចុះចែកខិត្តប័ណ្ណ **៥៥៥** លើក ស្មើនឹង **៨១.៨១២**សន្លឹក និងនៅតាមរោងចក្រ សហគ្រាស ពន្ធនាគារ អង្គភាព **៨៥** លើក អ្នកចូលរួម **៣.០១៨** នាក់ ស្រី **៨១០** នាក់ ។

សរុបអ្នកដែលបានមកទទួលសារអប់រំពីបញ្ហាគ្រឿងញៀន មានចំនួន **១.៨៤៥.៥០៣** អង្គ/នាក់ ធៀបត្រីមាសទី១ ឆ្នាំ២០១៩(**១.៣៤៧.៧២១ អង្គ/នាក់**) មានការកើនឡើងចំនួន **៤៩៧.៧៨២** អង្គ/នាក់។

**ជាមួយគ្នានេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន** បានបែងចែកឯកសារ និងសម្ភារអប់រំផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀនគ្រប់ប្រភេទ ដល់កម្មវិធីអប់រំផ្សព្វផ្សាយនានារបស់ក្រសួង ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត និងអង្គភាពពាក់ព័ន្ធ រួមមាន ៖ សៀវភៅច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន **២.២០០** ក្បាល , សៀវភៅចំណេះដឹងជាមូលដ្ឋានពីគ្រឿងញៀន **១.៥០០** ក្បាល , ខិត្តប័ណ្ណអប់រំផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀន **៨.៥០០** សន្លឹក, ផ្ទាំងរូបភាពអប់រំផ្សព្វផ្សាយពីគ្រោះថ្នាក់នៃគ្រឿងញៀន **១.០០០** សន្លឹក, សៀវភៅសរសេរសៀវភៅកំរងសំណួរ-ចម្លើយពីគ្រឿងញៀន និងសៀវភៅទិនានុលេខន៍ **៣.៧០០** ក្បាល , ប្រតិទិនលើតុ និងព្យួរជញ្ជាំង **២.០០០** ផ្ទាំង និងជញ្ជីងថ្លឹងថ្នាំញៀនចំនួន ១០ ។

**បាន និងកំពុងសម្របសម្រួល និងជំរុញអនុវត្តស្មារតីលទ្ធផលទស្សនកិច្ចការងាររបស់ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន** នៅសាធារណរដ្ឋប្រជាមានិតចិនកាលពីចុងឆ្នាំ២០១៩ កន្លងទៅ គឺបានសំណូមពរឲ្យភាគីចិនបន្តការគាំទ្រលើដំណើរការរៀបចំបណ្ណាល័យឌីជីថលអប់រំផ្សព្វផ្សាយពីគ្រឿងញៀន នៅតាមគ្រឹះស្ថានមធ្យមសិក្សា និងឧត្តមសិក្សា ។

## ២. ការកាត់បន្ថយគ្រោះថ្នាក់បណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន ព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងការចាកចេញពីគ្រឿងញៀន ។

អនុវត្តតាមគោលការណ៍ដឹកនាំ ឱ្យបន្តពង្រឹងគុណភាពព្យាបាលនៅតាមមន្ទីរពេទ្យជាតិ មន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព ពិសេសការបន្តបណ្តុះបណ្តាល និងរៀបចំគ្រូពេទ្យនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ ដែលបានបើកបម្រើសេវាសុខភាពផ្លូវចិត្ត និងភាពញៀនគ្រឿងញៀន សំដៅធានានិរន្តរភាពព្យាបាលអ្នកញៀនគ្រឿងញៀននៅតាមសហគមន៍ ។ បន្តពង្រឹងសមត្ថភាពមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋ និងឯកជន ធានាបាននូវប្រសិទ្ធភាពស្តារនីតិសម្បទា និងសមាហរណកម្ម ។ ជំរុញការដាក់ឲ្យដំណើរការមជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្តនិងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀននៅខេត្តព្រះសីហនុ និងឈានទៅបញ្ចប់គម្រោងសាងសង់ទាំងស្រុង ។ រៀបចំតម្លើងបញ្ជីឈ្មោះឃុំ-សង្កាត់គោលដៅចំនួន៤៥០ ដែលបានបើកបម្រើសេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍។ជំរុញការរៀបចំ និងពង្រឹងការគ្រប់គ្រងទិន្នន័យអ្នកញៀន និងអ្នកប្រើប្រាស់គ្រឿងញៀនឲ្យបានច្បាស់លាស់ និងមានលក្ខណៈជាប្រព័ន្ធ ។ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រសួង ស្ថាប័ន សមាជិក រួមនិងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត បានខិតខំបន្តអនុវត្តការងារដោយទទួលបាននូវលទ្ធផលដូចខាងក្រោម ៖

### ២.១.ការកាត់បន្ថយគ្រោះថ្នាក់បណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន ៖

ក្នុងត្រីមាសទី១ ដើមឆ្នាំ២០២០ នេះ ការអនុវត្តកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលមានក្រសួងសុខាភិបាលជាសេនាធិការ និងការគាំទ្រចំពោះអង្គការដៃគូ បានសម្របសម្រួល និងចាត់បញ្ជូនមន្ត្រីពាក់ព័ន្ធឲ្យទៅចូលរួមក្នុងកិច្ចប្រជុំ សិក្ខាសាលា និងធ្វើបទបង្ហាញ រួមមាន ៖

– កិច្ចប្រជុំលើកទី១ សម្រាប់ឆ្នាំ២០២០ ដើម្បីពិនិត្យលើវឌ្ឍនភាពការងារទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងគ្រឿងញៀននៅកន្លែងធ្វើការ

– សិក្ខាសាលា ក្រុមប្រឹក្សាបច្ចេកទេសលើកទី១របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។

– សិក្ខាសាលា ស្តីពីការអនុវត្តសកម្មភាពការងារឆ្នាំ២០១៩ និងទិសដៅផែនការសកម្មភាពឆ្នាំ២០២០ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។

## ២.២. ការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ៖

ត្រីមាសទី១ ឆ្នាំ២០២០នេះ ស្ថានភាពអ្នកប្រើប្រាស់ និងអ្នកញៀនគ្រឿងញៀន មានដូចខាងក្រោម ៖

– តាមរបាយការណ៍របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមណ្ឌលឯកជន ៖

- អ្នកដែលបានធ្វើសមាហរណកម្មចេញពីមណ្ឌល មាន **២.៨៣៣** នាក់(1)
- អ្នកដែលបន្តធ្វើការបន្សាបព្យាបាលនៅតាមមណ្ឌល មាន **៣.៩៦៨** នាក់(2) **ក្នុងនោះ ៖**

អាយុអ្នកប្រើប្រាស់ និងអ្នកញៀនគ្រឿងញៀន

| ៩ឆ្នាំចុះ | ពី១០-១៧ ឆ្នាំ | ពី១៨-២៥ ឆ្នាំ | ពី២៦-៣៥ឆ្នាំ | ពី៣៦-៤៥ ឆ្នាំ | ពី៤៥ឆ្នាំឡើង |
|---|---|---|---|---|---|
| | ៤,៨៤ % | ៣៧,៧៣ % | ៣៧,៥៧ % | ១៩,៨៦ % | ១ % |

ប្រភេទគ្រឿងញៀនដែលបានប្រើប្រាស់

| WY | ICE | អិចស្តាស៊ី | ហេរ៉ូអ៊ីន | កេតាមីន | កញ្ឆា | ការហិត | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ០,៨៤ % | ៩៨,០៨% | ០ | ០,៨១ % | ០ | ០,២៤ % | ០,០៣% | % |

មុខរបររបស់អ្នកប្រើប្រាស់ និងអ្នកញៀនគ្រឿងញៀន

| មន្ត្រីរាជការ | សិស្ស/និសិត្ស | អ្នកបម្រើតាមសេវាកម្សាន្ត | កម្មករ/ពលករ | អ្នកជំនួញ | មុខរបរមិនពិតប្រាកដ | ជនអនាថា | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ២,៣៤% | ៧,០៧% | ០,៥៥% | ២៩,៧៧% | ៨,១៧% | ៣១,៥៣% | ១០,០៦% | ១០,៥១% |

– តាមរបាយការណ៍របស់ក្រសួងសុខាភិបាល ៖

- អ្នកដែលបានមកទទួលសេវាពិនិត្យព្យាបាលនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ ក្នុងរាជធានីខេត្ត មានចំនួន **១.៨៨៦** នាក់(3) ។

– តាមរបាយការណ៍របស់លេខាធិការដ្ឋានយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៥ ត្រីមាសទី១ នេះ ក្នុងចំណោមជនសង្ស័យប្រើប្រាស់គ្រឿងញៀនដែលបានឃាត់ខ្លួនចំនួន **២.៣៤០** នាក់ គឺ ៖

- បានចាត់វិធានការបញ្ជូនទៅមណ្ឌលចំនួន **១.៣៨៨** នាក់
- បានធ្វើការអប់រំបញ្ជូនទៅមូលដ្ឋានវិញចំនួន **៦៣៧** នាក់
- បានចាត់វិធានការបញ្ជូនទៅពន្ធនាគារចំនួន **៣១៥** នាក់(4)

➢ តួលេខដែលត្រូវបានគិតបញ្ចូលទៅក្នុងចំនួនអ្នកប្រើប្រាស់គ្រឿងញៀនដែលយើងបានគ្រប់គ្រង **គឺ** អ្នកដែលបានចាត់វិធានការបញ្ជូនទៅពន្ធនាគារចំនួន **៣១៥ នាក់** ។

❖ សរុបតួលេខអ្នកប្រើប្រាស់ និងអ្នកញៀនគ្រឿងញៀន ដែលយើងគ្រប់គ្រងបានក្នុងត្រីមាសទី១ ឆ្នាំ២០២០ នេះ មានចំនួន **៨.៦៦២ នាក់** គឺស្មើនឹងយក(1)+(2)+(3)+(4) ។ ប្រៀបធៀបនឹងត្រីមាសទី១ ឆ្នាំ ២០១៩(**៨.៤៤៩**នាក់) កើនឡើង ២១៣ នាក់ ។

**ជាមួយគ្នានេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ៖**

– ជំរុញឲ្យគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ពង្រឹង និងបង្កើតគណៈកម្មការសម្របសម្រួលសម្រាប់ការព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ នៅតាមឃុំ-សង្កាត់ ដើម្បីគាំទ្រឲ្យអ្នកប្រើប្រាស់និងអ្នកញៀនគ្រឿងញៀនមានភាពងាយស្រួលទៅទទួលយកសេវាព្យាបាលនៅតាមមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក និងលើកកម្ពស់ការថែទាំបន្តនៅតាមសហគមន៍

– បាន និងកំពុងជំរុញរៀបចំឲ្យមានគណៈគ្រប់គ្រង កម្មវិធីការងារ និងបទដ្ឋានបច្ចេកទេសពាក់ព័ន្ធសម្រាប់ដំណើរការមជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ ដល់អ្នកញៀនគ្រឿងញៀននៅខេត្តព្រះសីហនុ និងឈានទៅបញ្ចប់គម្រោងសាងសង់ទាំងស្រុង

– បាន និងកំពុងជំរុញការងាររៀបចំទិន្នន័យអ្នកប្រើប្រាស់ និងអ្នកញៀនគ្រឿងញៀន ឲ្យស៊ីសង្វាក់គ្នារវាងស្ថាប័នអនុវត្តច្បាប់ ជាមួយនឹងស្ថាប័នផ្តល់សេវាសុខភាព និងសេវាសង្គមកិច្ច

– បាន និងកំពុងសម្របសម្រួល និងជំរុញអនុវត្តស្មារតីនៃ**លទ្ធផលទស្សនកិច្ចការងាររបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន** នៅសាធារណរដ្ឋប្រជាមានិតចិន កាលពីចុងឆ្នាំ២០១៩ កន្លងទៅ ដូចជា ការស្នើសុំជំនួយជាសម្ភារបរិក្ខា និងបណ្តុះបណ្តាលជំនាញសម្រាប់មជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ ដល់អ្នកញៀនគ្រឿងញៀននៅខេត្តព្រះសីហនុ និងការស្នើជួយជំរុញជំនួយសាងសង់មជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅខេត្តពោធិ៍សាត់ ។

**ដោយឡែកក្រសួងសុខាភិបាល** ក្នុងត្រីមាសទី១ ដើមឆ្នាំ២០២០ នេះ ក៏ដូចជានៅក្នុងចុងឆ្នាំ២០១៩ បានដំណើរការសេវាពិនិត្យព្យាបាលជំងឺផ្លូវចិត្ត និងភាពញៀនគ្រឿងញៀនបាន**៤៥០**កន្លែង នៅទូទាំងប្រទេស ក្នុងនោះ ៖ មន្ទីរពេទ្យថ្នាក់ជាតិ២កន្លែង, មន្ទីរពេទ្យខេត្ត២៤កន្លែង , មន្ទីរពេទ្យបង្អែក ៧៣កន្លែង និងមណ្ឌលសុខភាព ៣៥១កន្លែង ។ បានដំឡើងស្លាកសញ្ញាសម្គាល់ទីតាំងផ្តល់សេវាពិនិត្យព្យាបាលជំងឺផ្លូវចិត្ត និងភាពញៀនគ្រឿងញៀនបាន៣៤៥ទីតាំង ស្មើ នឹង៨២%លើចំនួនទីតាំងផ្តល់សេវាសរុប។**ជាមួយគ្នានេះ ក្នុងចំនួនមូលដ្ឋានដែលបានដំណើរការសេវាពិនិត្យព្យាបាលជំងឺផ្លូវចិត្ត និងភាពញៀនគ្រឿងញៀនទាំង ៤៥០កន្លែង យើងមានវេជ្ជបណ្ឌិត និងគ្រូពេទ្យ ៨៨៣ នាក់ (ស្រី ២៣០នាក់)** ក្នុងនោះ នៅមន្ទីរពេទ្យជាតិ២កន្លែង មានវេជ្ជបណ្ឌិត និងគ្រូពេទ្យ៣៨នាក់(ស្រី០៩នាក់),មន្ទីរពេទ្យបង្អែក៩៨ កន្លែង មានវេជ្ជបណ្ឌិត និងគ្រូពេទ្យ ៣២៤ នាក់(ស្រី៨២នាក់) និងនៅមណ្ឌលសុខភាព ៣៥០កន្លែង មានវេជ្ជបណ្ឌិត និងគ្រូពេទ្យ៥២១នាក់(ស្រី១៣៩នាក់) ។

### ២.៣. ការពង្រឹងសមត្ថភាពព្យាបាល និងស្តារនីតិសម្បទា ៖

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលមានក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាសេនាធិការ បានរៀបចំ ៖

– កិច្ចប្រជុំមួយចំនួន ដូចជា ៖ ក្រុមការងារបច្ចេកទេសសម្រាប់ការគ្រប់គ្រងមជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀននៅខេត្តព្រះសីហនុ,ពិនិត្យពិភាក្សាលើការកែសម្រួលសេចក្តីព្រាងសេចក្តីសម្រេច ស្តីពីការកែសម្រួលសមាសភាពគណៈកម្មាធិការទទួលបន្ទុកព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងការកែសម្រួលអនុក្រឹត្យស្តីពីការបង្កើតមជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន

– ទស្សនកិច្ចសិក្សាលើការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅប្រទេសថៃ

– ចុះសិក្សាស្វែងយល់ និងពង្រឹងការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅតាមខេត្តគោលដៅមួយចំនួន ។

**( លទ្ធផលសកម្មភាពការងារលម្អិតមាននៅក្នុងតារាងឧបសម្ព័ន្ធ )**

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តច្បាប់

អនុវត្តតាមគោលការណ៍ដឹកនាំ ឱ្យបន្តពង្រឹងប្រសិទ្ធភាពអនុវត្តច្បាប់ ដើម្បីបំផ្លាញអង្គការចាត់តាំងឧក្រិដ្ឋជនគ្រឿងញៀន ដោយបង្កើនកិច្ចសហប្រតិបត្តិការជាមួយអន្តរជាតិ តំបន់ អនុតំបន់ ពិសេសសហការយ៉ាងជិតស្និទ្ធជាមួយប្រទេសជិតខាង ដើម្បីទប់ស្កាត់ការហូរចូលនូវគ្រឿងញៀនគ្រប់ប្រភេទ នៅតាមតំបន់ព្រំដែន។ បន្ត

ពង្រឹងការអនុវត្តវិធានការរដ្ឋបាល និងចាត់វិធានការបង្រ្កាបនៅតាមក្លឹបកម្សាន្ត និងទីតាំងសប្បាយដ្ឋានដែលពាក់ព័ន្ធនឹងគ្រឿងញៀន ។ បន្តពង្រឹង និងពង្រីកការិយាល័យទំនាក់ទំនងព្រំដែន(BLO) ក៏ដូចការលើកកម្ពស់ជំនាញមន្ត្រីមន្ទីរពិសោធន៍គ្រឿងញៀន។ បន្តស្រាវជ្រាវ និងបង្ក្រាបករណីផលិតកែច្នៃគ្រឿងញៀន និងករណីដាំដុះដំណាំកញ្ឆា ។ ពន្លឿនការបង្កក ជំរុញនីតិវិធីរឹបអូស និងលក់ទ្រព្យដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ។ បន្តអនុវត្តឱ្យបានម៉ឺងម៉ាត់ការចូលរួមក្នុងនីតិវិធីតុលាការរឿងក្តីបទល្មើសគ្រឿងញៀន តាមស្មារតីច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ក៏ដូចជាការបន្តពង្រឹងសមត្ថភាពកសាងសំណុំរឿងបទល្មើសគ្រឿងញៀនរបស់មន្ត្រីអនុវត្តច្បាប់។បន្តពង្រឹងសមត្ថភាព ឆន្ទៈ គុណធម៌ស្មោះត្រង់នឹងវិជ្ជាជីវៈរបស់មន្ត្រីអនុវត្តច្បាប់ តាមទិសស្លោកពាក្យ ១រាយការណ៍របស់ **សម្តេចក្រឡាហោម ស ខេង** គឺ ៖ ១-កុំឲ្យពាក់ព័ន្ធ ២-កុំអន្តរាគមន៍ ៣-កុំលើកលែង និងត្រូវរាយការណ៍គ្រប់ករណីបទល្មើសគ្រឿងញៀន ។ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តសហការសម្រប សម្រួលជាមួយស្ថាប័នអនុវត្តច្បាប់ ទាំងក្នុងក្របខណ្ឌជាតិ និងអន្តរជាតិ ក្នុងការពង្រឹងការអនុវត្តវិធានការអនុវត្តច្បាប់ ក៏ដូចជាបានពង្រឹងការអនុវត្តវិធានការរដ្ឋបាលផងនោះ យើងទទួលបាននូវលទ្ធផលដូចខាងក្រោម ៖

### ៣.១. ការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានសម្របសម្រួល រៀបចំ និងចូលរួមកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាលសំខាន់ៗ រួមមាន ៖

– កិច្ចប្រជុំត្រួតពិនិត្យ និងពិគ្រោះយោបល់ ស្តីពីការងារការិយាល័យទំនាក់ទំនងព្រំដែន(BLO) នៅតាមបណ្តោយព្រំដែនកម្ពុជា-ឡាវ កម្ពុជា-ថៃ និងកម្ពុជា-វៀតណាម

– ផ្តល់បទឧទ្ទេសនាមអំពីចំណេះដឹងជាមូលដ្ឋាននៃគ្រឿងញៀន និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដល់សិស្សថ្នាក់មូលដ្ឋានជំនាន់ទី១១ នៅវិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាល នៃកងយោពលខេមរភូមិន្ទ និងនៅវិទ្យាស្ថានកងរាជអាវុធហត្ថកំបូល

– វគ្គបណ្តុះបណ្តាលបំប៉នជំនាញបង្ការ និងបង្ក្រាបគ្រឿងញៀននៅបណ្ឌិត្យសភានគរបាលកម្ពុជា

– កិច្ចប្រជុំពិភាក្សាលើការត្រៀមចូលរួមសកម្មភាពក្នុងលំហាត់អនុវត្ត ស្តីពីការងារប្រយុទ្ធប្រឆាំងបទល្មើសឆ្លងដែន ដើម្បីលើកកម្ពស់និងពង្រឹងយន្តការត្រួតពិនិត្យតាមព្រំដែន ដោយប្រើប្រាស់យន្តការការិយាល័យទំនាក់ទំនងព្រំដែនBLO ។ **ជាមួយគ្នានេះ ៖**

– អគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជា និងក្រសួងនគរបាលវៀតណាម បានបើកកិច្ចប្រជុំពិភាក្សាអំពីលទ្ធផល និងបទពិសោធន៍ក្នុងការអនុវត្តផែនការចំណុចខ្ពស់នៃយុទ្ធនាការ ការឃោសនា និងបង្ក្រាបបទល្មើសគ្រឿងញៀននៅតាមបណ្តោយព្រំដែនកម្ពុជា វៀតណាម កន្លងមក

– បាន និងកំពុងជំរុញ និងសម្របសម្រួលអនុវត្តផែនការ ស្តីពីយុទ្ធនាការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រឿងញៀននៅតាមបណ្តោយព្រំដែនកម្ពុជា វៀតណាម របស់ក្រសួងមហាផ្ទៃ ។

– **ក្នុងដំណើរទស្សនកិច្ចរបស់គណៈប្រតិភូជាន់ខ្ពស់ក្រសួងមហាផ្ទៃ ដឹកនាំដោយ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** កាលពីដើមខែមីនា ឆ្នាំ២០២០ កន្លងទៅ នៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ភាគីទាំងពីរ(កម្ពុជា-ឡាវ) បានឯកភាពគ្នាបន្តសហការចាត់វិធានការម៉ឺងម៉ាត់ទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រឿងញៀនឆ្លងកាត់ព្រំដែននៃប្រទេសទាំងពីរ ព្រមទាំងសហការផ្លាស់ប្តូរ ព័ត៌មាន និងបទពិសោធន៍ទៅវិញទៅមកពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ពិសេសជំរុញការបង្កើតភូមិ-ឃុំ/សង្កាត់ និងសាលារៀនគ្មានគ្រឿងញៀននៅតាមតំបន់ព្រំដែន ។

### ៣.២. លទ្ធផលបង្ក្រាបបទល្មើសគ្រឿងញៀន [1] ៖

– បទល្មើសគ្រឿងញៀនសរុប បង្ក្រាបបាន **២.៦៦០** ករណី(ត្រីមាសទី១/២០១៩ **២.០៤៧**ករណី) កើនលើស **៦១៣** ករណី ស្មើនឹង **២៩,៩៥** % ក្នុងនោះ ៖

- ករណីជួញដូរ រក្សាទុក **១.៦២០** ករណី
- ករណីប្រើប្រាស់ **១.០២២** ករណី
- ដាំដុះ **១៧** ករណី
- កែច្នៃ **០១** ករណី

– **ជនសង្ស័យសរុប** ឃាត់ខ្លួនមាន **៥.៣១៣** នាក់/ស្រី **៣៣០** នាក់(ត្រីមាសទី១/២០១៩ **៤.៤៣៤** នាក់) កើនលើស **៨៧៩** នាក់ ស្មើនឹង **១៩,៨២** % ក្នុងនោះ ៖

- ជនសង្ស័យក្នុងករណីជួញដូរ រក្សាទុក **២.៩៦៣** នាក់ (ស្រី ២៤៣ នាក់)
- ជនសង្ស័យក្នុងករណីប្រើប្រាស់គ្រឿងញៀន **២.៣៤០** នាក់ (ស្រី ៨៦ នាក់)
- ជនសង្ស័យក្នុងករណីដាំដុះ **០៨** នាក់ ភេទប្រុស
- ជនសង្ស័យក្នុងករណីកែច្នៃ **០២** នាក់ (ស្រី ០១ នាក់)

ជនសង្ស័យរួមមាន ៖ ជនជាតិ**ខ្មែរ ៥.២២៦ នាក់(ស្រី ៣១៦ នាក់) និងជនបរទេស ៨៧ នាក់ (ស្រី១៤នាក់)** ស្មើនឹង០៩ជនជាតិ គឺ ៖ វៀតណាម ៥៥ នាក់(ស្រី១៣នាក់) , ចិន ១៦ នាក់ , ឡាវ ០៣ នាក់ , ថៃ ០៥ នាក់(ស្រី០១នាក់) , ឥណ្ឌូនេស៊ី ០១ នាក់ , ហ្វីលីពីន ០២ នាក់ ,សឹង្ហបូរី ០២ នាក់ ជប៉ុន ០១ នាក់ និង ជនជាតិអង់គ្លេស ០២ នាក់ ភេទប្រុស ។

– **គ្រឿងញៀនសរុប** ចាប់យកបានចំនួន **១០១** គ.ក្រ **៩១៣,៥១** ក្រាម (ត្រីមាសទី១/ឆ្នាំ២០១៩ **១០០** គ.ក្រ **០៧៧,១២** ក្រាម) កើនលើស **០១** គ.ក្រ **៨៣៦,៦៩** ក្រាម ស្មើនឹង **១,៨៣** % ក្នុងនោះ ៖

- មេតំហ្វេតាមីនក្រាមម្សៅ (ICE) ៨១ គ.ក្រ ៦៧០,២៨ ក្រាម
- មេតំហ្វេតាមីនគ្រាប់ (WY) ៥៣៣,៧៩ ក្រាម
- អិចស្តាស៊ី ០២ គ.ក្រ ៤១១,៩០ ក្រាម
- កេតាមីន ០៨ គ.ក្រ ២៩៣,៤៦ ក្រាម
- Nimetazapam ០៩ គ.ក្រ ០០៤,១៨ ក្រាម

– **កញ្ឆាស្រស់** កាប់បំផ្លាញដើមកញ្ឆាបានចំនួន ៧៧.៧០៨ ដើម

– **កញ្ឆាក្រៀម** ចំនួន ២២៥ គ.ក្រ ២៣៧ ក្រាម

– **សារធាតុគីមី** ចំនួន ០២ គ.ក្រ ០៩០ ក្រាម

– **សម្ភារចាប់យក** ក្នុងប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន ដែលបានបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត រួមមាន ៖ រថយន្ត ២៦ គ្រឿង , ម៉ូតូ ៦៥៧ គ្រឿង ,ទូរស័ព្ទ ១.៩៤៣ គ្រឿង, ជញ្ជីង ១២៨ គ្រឿង, អាវុធវែង ០៨ ដើម, អាវុធខ្លី ០៣ ដើម , ប្រាក់កម្ពុជា ៦៥.១៣១.១០០ រៀល , ប្រាក់អាមេរិក ២៨.៨៩៦ ដុល្លារ , ប្រាក់ថៃ ១៣៧.៧៦៥ បាត , ប្រាក់វៀតណាម ៣.១១០.០០០ ដុង ។

– **ជនសង្ស័យ**ចាប់ខ្លួនតាមដីកាមាន ១១០ដីកា ឃាត់ខ្លួនជនសង្ស័យ ១០៣នាក់(ស្រី ០៣នាក់) ។

➢ <u>**កត់សម្គាល់**</u> **បទល្មើសគ្រឿងញៀនធំៗ** ដែលមានប្រភពហូរចូលតាមច្រកព្រំដែនគោកនៃភាគឦសាន ភាគខាងលិច និងមានការលួចនាំចេញទៅព្រំដែនភាគខាងកើតប្រទេស ត្រូវបានសមត្ថកិច្ចជំនាញស្រាវជ្រាវរកឃើញ និងបង្ក្រាបបាន **រួមមាន** ៖

---

1 ) បទល្មើស ជនសង្ស័យ វត្ថុតាងគ្រឿងញៀន ទ្រព្យសម្បត្តិ យកតាមតារាងយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀន

- ករណីចាប់ពី០១គីឡូក្រាមឡើង មាន**១២ករណី** ឃាត់ខ្លួនជនសង្ស័យបាន**២០នាក់**(ស្រី០៣នាក់) មានមេក្លោង ០៦ នាក់ និងបណ្ដាញ ១៤ នាក់ ក្នុងនោះ មានជនជាតិខ្មែរ**១៤នាក់** ជនជាតិឡាវ**០១នាក់** ជនជាតិជប៉ុន**០១នាក់** ជនជាតិសឹង្ហបុរី**០១នាក់** និងជនជាតិចិន**០៣នាក់** និងរឹបអូសគ្រឿងញៀនសរុបបាន **៧៥ គីឡូក្រាម ៩៥៨,១០ ក្រាម** ។
- ករណីចាប់ពី**១០០ក្រាម** ដល់ **៩៩៩ ក្រាម** មាន**២៨ករណី** ឃាត់ខ្លួនជនសង្ស័យបាន**៧៤នាក់** (ស្រី១០នាក់) មានមេក្លោង **១២ នាក់** និងបណ្ដាញ **៦២ នាក់** ក្នុងនោះ មានជនជាតិខ្មែរ**៧០នាក់(ស្រី១០នាក់)** និងជនជាតិចិន**០៤នាក់ ភេទប្រុស** និងរឹបអូសគ្រឿងញៀនសរុបបាន ០៨ **គីឡូក្រាម ៧៣១,៩៣ ក្រាម** ។

(**ករណីលម្អិតនីមួយៗនៃការបង្ក្រាបបទល្មើសគ្រឿងញៀនធំៗ មាននៅក្នុងតារាងឧបសម្ព័ន្ធ**)

### ៣.៣. ការអនុវត្តវិធានការរដ្ឋបាល ៖

អនុវត្តវិធានការរដ្ឋបាលបានចំនួន **៤០២ លើក** ក្នុងនោះ បានអញ្ជើញម្ចាស់អាជីវកម្ម និងអ្នកពាក់ព័ន្ធមកស្ដាប់ការណែនាំចំនួន **២០៧ លើក** ស្មើនឹង ៨.៦០២ **នាក់**/ស្រី៤.២៤៥នាក់ និងចុះអប់រំម្ចាស់ទីតាំងអាជីវកម្មចំនួន **១៩៥ លើក** **និង០៣គោលដៅ**(ផ្ទះសំណាក់០៧ ផ្ទះជួល**១៨៧** ខារ៉ាអូខេ០១) ។ **ទន្ទឹមនោះ** ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត បានចុះធ្វើតេស្តរកសារធាតុញៀនលើក្មេងទំនើង ជនមានតម្រុយប្រើប្រាស់គ្រឿងញៀននិងធ្មក់ត្រួតពិនិត្យអ្នកបើកបររថយន្តដឹកទំនិញ ដឹកកម្មករ ដឹកអ្នកដំណើរ បុគ្គលិកក្លឹបកម្សាន្ត កាស៊ីណូ សណ្ឋាគារ ខារ៉ាអូខេ សរុបចំនួន **១៨៩ លើក** ស្មើនឹង **១.៧៦៤ នាក់/ស្រី ២៥ នាក់** **រកឃើញអ្នកផ្ទុកសារធាតុញៀន ៣៧២ នាក់** ត្រូវបានសមត្ថកិច្ចធ្វើការបញ្ជូនតាមនីតិវិធីច្បាប់ឲ្យទៅទទួលយកសេវា បន្សាប និងព្យាបាល ។

**ជាមួយគ្នានេះ បាន និងកំពុងជំរុញ និងសម្របសម្រួលអនុវត្តស្មារតីលទ្ធផលនៃទស្សនកិច្ចការងាររបស់ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន** នៅសាធារណរដ្ឋប្រជាមានិតចិន កាលពីចុងឆ្នាំ២០១៩ កន្លងទៅ គឺបានសំណូមពរដល់ភាគីចិនឲ្យជួយជាសម្ភារ និងបរិក្ខាសម្រាប់ស្វែងរកសារធាតុញៀន ដើម្បីបំពាក់ជូនអង្គភាពអនុវត្តច្បាប់ ។

### ៣.៤. លទ្ធផលកោសល្យវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន ៖

មន្ទីរពិសោធន៍គ្រឿងញៀននៃអ.ជ.ប.គ.ញ. បានធ្វើកោសល្យវិច័យលើសំណាកវត្ថុតាងដែលសង្ស័យជាគ្រឿងញៀនក្នុងត្រីមាសទី១ ដើមឆ្នាំ២០២០នេះ បានចំនួន **២.១២៨** សំណាក= **១.៩៣៦** ករណី ក្នុងនោះ ៖

- **សំណាកវិជ្ជមានសារធាតុញៀន ២.០៣៦** សំណាក (៩៥,៦៧ %) = **១.៨៩៧** ករណី គឺ ៖
  - មេតំហ្វេតាមីនក្រាមម្សៅ (ICE) ១.៨៩៨ សំណាក (៨៩,១៩ %)
  - មេតំហ្វេតាមីនគ្រាប់ (WY) ៣២ សំណាក ( ១,៥០%)
  - កេតាមីន ៣៥ សំណាក ( ១,៨៣ %)
  - កូកាអ៊ីន ១ សំណាក ( ០,០៤ %)
  - MDMA ៤៨ សំណាក ( ២,២៥ %)
  - នីមេតាហ្សេប៉ាម ១០ សំណាក ( ០,៤៦ %)
  - ហេរ៉ូអ៊ីន ៤ សំណាក ( ០,១៨ %)
  - សារធាតុកញ្ឆា ៤ សំណាក ( ០,១៨ %)
- **សំណាកអវិជ្ជមានសារធាតុញៀន ៩២** សំណាក = **៣៩** ករណី (៤,៣៥ %)
- ផ្តល់ដល់ស្ថាប័នអនុវត្តច្បាប់រួមមាន៖ស្នងការដ្ឋាននគបាលរាជធានីភ្នំពេញ ខេត្តត្បូងឃ្មុំ កំពង់ស្ពឺ កោះកុង ព្រះវិហារ កំពង់ឆ្នាំង សៀមរាប ឧត្តរមានជ័យ បន្ទាយមានជ័យ ក្រចេះ ពោធិ៍សាត់ កំពត និងខេត្តកណ្ដាល ,

បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តកណ្ដាល និងមន្ទីរប្រឆាំងគ្រឿងញៀន ដូចជា ៖ ស្រោមសំបុត្ររក្សាវត្ថុតាងគ្រឿងញៀនចំនួន ៨៥០ សន្លឹក តេស្តរកសារធាតុញៀនឈ្មោះ ម៉ាគ្វីតេស្តចំនួន ១.១៨០តេស្ត និងស៊ីម៉ុនតេស្តចំនួន ២០០ មិល្លីលីត្រ តេស្តរកសារធាតុញៀនក្នុងទឹកមូត្រប្រភេទ ៖ មេតំហ្វេតាមីន អិចស្តាស៊ី ម័រហ្វីន និងកេតាមីនចំនួន ៣.១៨០តេស្ត ។

## ៣.៥. ចំណាត់ការរឿងក្តីពាក់ព័ន្ធបទល្មើសគ្រឿងញៀនរបស់រាជធានី-ខេត្ត ៖

ក្នុងត្រីមាសទី១ ឆ្នាំ២០២០ នេះ ចំណាត់ការរឿងក្តីលើសំណុំរឿងពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន របស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី ខេត្ត ដែលបូកសរុបដោយក្រសួងយុត្តិធម៌ រួមមាន ៖

❖ **ដំណាក់កាលអយ្យការ ៖**

– **សំណុំរឿងសរុបចំនួន ១.៩០១ រឿង**

– **ជនល្មើសសរុបចំនួន ៣.៤៤៣ នាក់** រួមមានជនល្មើសជា ៖ នីតិជនចំនួន ៣.០២០ នាក់(ស្រី ២២៤ នាក់) និងជាអនីតិជនចំនួន ១៨៥ នាក់(ស្រី ១៤ នាក់) ក្នុងនោះ ៖ ជនល្មើសជាប់ឃុំសរុបចំនួន ១.៥៥៧ នាក់ និងជនល្មើសនៅក្រៅឃុំសរុបចំនួន ១.៨៨៦ នាក់ ។

❖ **ដំណាក់កាលស៊ើបសួរ ៖**

– **សំណុំរឿងសរុបចំនួន ១.៨៥៤ រឿង**

– **ជនត្រូវចោទសរុបចំនួន ២.៣១០ នាក់** រួមមានជនល្មើសជា៖ នីតិជនចំនួន ២.០៣៦ នាក់(ស្រី ១៣៥ នាក់) និងជាអនីតិជនចំនួន ១២៩ នាក់(ស្រី១០នាក់) ក្នុងនោះ ៖ ជនត្រូវចោទជាប់ឃុំសរុបចំនួន ២.២២០ នាក់ និងជនត្រូវចោទនៅក្រៅឃុំសរុបចំនួន ៩០ នាក់ ។

❖ **ដំណាក់កាលជំនុំជម្រះ ៖**

– **សំណុំរឿងសរុបចំនួន ១.៨៩៨ រឿង**

– **ជនជាប់ចោទសរុបចំនួន ៣.០៦២ នាក់** រួមមានជនល្មើសជា៖ នីតិជនចំនួន ២.៧១១ នាក់(ស្រី ១៨២ នាក់) និងជាអនីតិជនចំនួន ១៥៣ នាក់(ស្រី ១៦ នាក់) ក្នុងនោះ ៖ ជនជាប់ចោទជាប់ឃុំសរុបចំនួន ២.៥១៩ នាក់ និងជនជាប់ចោទនៅក្រៅឃុំសរុបចំនួន ៥៤៣ នាក់ ។

**(ទិន្នន័យលម្អិតនៃដំណាក់កាលនីមួយៗមានក្នុងតារាងឧបសម្ព័ន្ធ)**

## ៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ

អនុវត្តតាមគោលការណ៍ដឹកនាំ ឱ្យបង្កើនការយកចិត្តទុកដាក់គ្រប់គ្រង ត្រួតពិនិត្យសារធាតុគីមីផ្សំ វត្ថុធាតុដើម ព្រមទាំងសារធាតុផ្សំផ្សេងទៀត ដើម្បីបង្ការ និងទប់ស្កាត់ការបង្វែរពីជំនួញស្របច្បាប់យកទៅផលិតគ្រឿងញៀនខុសច្បាប់ យើងបានរៀបចំលិខិតបទដ្ឋានគតិយុត្ត និងចូលរួមសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការគ្រប់គ្រងត្រួតពិនិត្យសារធាតុគីមីផ្សំ ក្នុងនោះ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ.បានចូលរួមសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការប្រមូលព័ត៌មាន និងត្រួតពិនិត្យឯកសារការអនុញ្ញាតឲ្យនាំចូលនូវសារធាតុញៀន និងសារធាតុគីមីផ្សំ ដែលបានកំណត់ក្នុងតារាងឧបសម្ព័ន្ធ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ជាក់ស្តែងក្នុងត្រីមាសទី១ ឆ្នាំ២០២០ នេះ បាននាំចូលសរុបចំនួន **៤.០០៨.៦៩២**គ.ក្រ **៨៧០**ក្រាម និង **១៣**លីត្រ ក្នុងនោះ ៖

➢ តារាងទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ៖

– ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានផ្តល់អាជ្ញាប័ណ្ណនាំចូល ឬចែកចាយសារធាតុគីមីផ្សំចំនួន **៤៨៨.៨៥៦** គ.ក្រ និង **១៣លីត្រ**

– ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ផ្តល់អាជ្ញាប័ណ្ណនាំចូលសារធាតុគីមីផ្សំ ចំនួន **៣.៥១៩.៦៥៩** គ.ក្រ។

➢ តារាងទី២ និងទី៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ៖

ក្រសួងសុខាភិបាល បានផ្តល់អាជ្ញាប័ណ្ណនាំចូលសារធាតុញៀន ជាវត្ថុធាតុដើម ចំនួន**១៧៥**គ.ក្រ និង ឱសថមានផ្ទុកសារធាតុញៀន ចំនួន **២**គ.ក្រ **៨៧០ក្រាម**។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

អនុវត្តតាមគោលការណ៍ដឹកនាំ ឱ្យបន្តអនុវត្តនូវរាល់កិច្ចការដែលបានព្រមព្រៀងគ្នាកន្លងមក ជាមួយភាគី ថៃ ឡាវ និងវៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែន ការអនុវត្តគម្រោងសុវត្ថិ-ភាពទន្លេមេគង្គសម្រាប់ប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម ការរៀបចំបង្កើតភូមិ-ឃុំ/សង្កាត់ ស គ្មានគ្រឿងញៀននៅតាមបណ្តោយព្រំដែន និងការពង្រឹងពង្រីកការិយាល័យទំនាក់ទំនងព្រំដែន (ការិ.**BLO**) នៅតាមព្រំដែនកម្ពុជា-ឡាវ កម្ពុជា-ថៃ និងកម្ពុជា-វៀតណាម ក៏ដូចជាចំពោះមុខនេះ ណែនាំឲ្យខេត្ត-ក្រុងជាប់ព្រំដែន ត្រូវជ្រើសរើសឃុំ-សង្កាត់០១ក្នុងខេត្ត ក្រុង ដើម្បីអនុវត្តផែនការភូមិ-ឃុំ/សង្កាត់ ស គ្មានគ្រឿងញៀន ។ ក្នុងត្រីមាសទី១ ដើមឆ្នាំ២០២០ នេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានចូលរួម និងសហការសម្របសម្រួលអនុវត្តយន្តការនៃកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនក្នុងក្របខ័ណ្ឌទ្វេភាគីជាមួយប្រទេសជាប់ព្រំដែន តាមរយៈ ៖

- ការចូលរួមសន្និសីទអាស៊ានលើកទី២ ស្តីពីការបង្ការបទឧក្រិដ្ឋ និងព្រហ្មទណ្ឌកម្រិតធ្ងន់ នៅប្រទេសថៃ
- ការពង្រឹងយន្តការអនុវត្តផែនការភូមិ-ឃុំ/សង្កាត់ ស គ្មានគ្រឿងញៀននៅតាមព្រំដែនកម្ពុជា-ឡាវ កម្ពុជា-ថៃ និងកម្ពុជា-វៀតណាម ។

**(លទ្ធផលសកម្មភាពការងារលម្អិតមាននៅក្នុងតារាងឧបសម្ព័ន្ធ)**

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់និងដៃគូអភិវឌ្ឍន៍នានា

អនុវត្តតាមគោលការណ៍ដឹកនាំ ឱ្យបន្តអនុវត្តខ្លឹមសារនៃកិច្ចព្រមព្រៀងនានា ទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគីជាមួយបណ្តាប្រទេសក្នុងអនុតំបន់ តំបន់ អន្តរជាតិ អង្គការ**UNODC**និងគម្រោងសហប្រតិបត្តិការជាមួយដៃគូពាក់ព័ន្ធ ក៏ដូចគម្រោងសុវត្ថិភាពទន្លេមេគង្គ(Safe Mekong Project) ។ ក្នុងត្រីមាសទី១ ដើមឆ្នាំ២០២០ នេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានចូលរួមសហការសម្របសម្រួលអនុវត្តក្នុងភាពជាដៃគូនៃកិច្ចសហប្រតិ-បត្តិការត្រួតពិនិត្យគ្រឿងញៀន តាមរយៈជំនួបពិភាក្សាការងារ ចូលរួមកិច្ចប្រជុំ និងសន្និសីទ មានជាអាទិ៍ ៖

- ជំនួបពិភាក្សាការងារ ជាមួយតំណាងអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC) អំពីការត្រៀមរៀបចំកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់នៃបណ្តាប្រទេសMOU នៅកម្ពុជា ការរៀបចំសិក្ខាសាលាថ្នាក់តំបន់ SMART និងកិច្ចសហប្រតិបត្តិការប្រឆាំងនឹងការជួញដូរគ្រឿងញៀន ការចរាចរសារធាតុគីមីផ្សំឆ្លងកាត់ព្រំដែន
- កិច្ចប្រជុំ ស្តីពីកិច្ចប្រតិបត្តិការនៅក្នុងតំបន់ត្រីកោណមាស(ប្រតិបត្តិការ១៥១១)
- កិច្ចប្រជុំ ស្តីពីប្រតិបត្តិការអនុវត្តច្បាប់គ្រឿងញៀននៅតំបន់អាស៊ី-ប៉ាស៊ីហ្វិកលើកទី២៥(ADEC 25) នៅប្រទេសជប៉ុន
- កិច្ចប្រជុំ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងសារធាតុគីមីផ្សំ នៅប្រទេសមីយ៉ាន់ម៉ា
- កិច្ចប្រជុំគណៈកម្មការគ្រឿងញៀនអង្គការសហប្រជាជាតិ លើកទី៦៣ នៅប្រទេសអូទ្រីស

**(លទ្ធផលសកម្មភាពការងារលម្អិតមាននៅក្នុងតារាងឧបសម្ព័ន្ធ)**

## ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

អនុវត្តតាមគោលការណ៍ដឹកនាំ ឱ្យជំរុញ និងពន្លឿននីតិវិធីពិនិត្យសេចក្តីព្រាងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ បន្តជំរុញ និងសម្របសម្រួលរៀបចំសមាសភាពរបស់គណៈកម្មការភូមិ-ឃុំ/

សង្កាត់ ស គ្មានគ្រឿងញៀន ទៅក្នុងសមាសភាពគណៈកម្មការដឹកនាំ និងអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព នៅគ្រប់លំដាប់ថ្នាក់ ជាយន្តការតែមួយ ។ បន្តការពង្រឹងយន្តការសេនាធិការ ដើម្បីអនុវត្ត និងដឹកនាំការងារពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ទាំងនៅថ្នាក់ជាតិ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ។ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រួមជាមួយក្រសួង ស្ថាប័ន សមាជិក និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ខិតខំអនុវត្តការងារដោយទទួលបាននូវលទ្ធផលដូចខាងក្រោម ៖

**៧.១.** បានបន្តដឹកនាំគណៈកម្មការទាំង៦ និងអនុគណៈកម្មការទាំង៣ នៃផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៥ ។

**៧.២.** បាន និងកំពុងបន្តនីតិវិធីពិនិត្យ និងកែសម្រួលជាមួយក្រសួងយុត្តិធម៌ លើសេចក្តីព្រាងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**៧.៣.** បាន និងកំពុងបន្តរៀបចំសេចក្តីព្រាងគោលនយោបាយជាតិ និងគោលការណ៍ណែនាំសម្រាប់ការរៀបចំបង្កើតភូមិ-ឃុំ/សង្កាត់ ស គ្មានគ្រឿងញៀន ។ **ជាមួយគ្នានេះ បាន និងកំពុងជំរុញ និងសម្របសម្រួលអនុវត្តស្មារតីលទ្ធផលទស្សនកិច្ចការងាររបស់ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**នៅសាធារណរដ្ឋប្រជាមានិតចិន កាលពីចុងឆ្នាំ២០១៩កន្លងទៅ គឺបានសំណូមពរឲ្យភាគីចិនបន្តការគាំទ្រជាសម្ភារបច្ចេកទេសក្នុងការអនុវត្តផែនការភូមិ-ឃុំ/សង្កាត់ ស គ្មានគ្រឿងញៀន ពិសេសនៅតាមបណ្តាគោលដៅជាប់ព្រំដែន ។

**(លទ្ធផលសកម្មភាពការងារលម្អិតមាននៅក្នុងតារាងឧបសម្ព័ន្ធ)**

## ៨. មូលនិធិជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

ចាប់ពីពេលបង្កើតមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានកៀរគរ និងប្រមូលបានមូលនិធិសរុបចំនួន **៥.១៣២.៣២៣** ដុល្លារ(ប្រាំលានមួយរយសាមសិបពីរពាន់និងបីរយម្ភៃបីដុល្លារអាមេរិក) ដែលថវិកានេះបានមកពីការចូលរួមរបស់សប្បុរសជន តាមរយៈមូលនិធិជួយសង្គ្រោះអ្នកញៀនគ្រឿងញៀនរបស់**សម្តេចក្រឡាហោម** ចំនួន **៣២៩.៩២៨** ដុល្លារ(បីរយម្ភៃប្រាំបួនពាន់ និងប្រាំបួនរយម្ភៃប្រាំបីដុល្លារអាមេរិក) ការលក់ទ្រព្យសម្បត្តិដែលបានមកពីការរឹបអូសដីនិងផ្ទះ៣កន្លែងចំនួន**២.៤០៤.៣៩៥**ដុល្លារ (ពីរលានបួនរយបួនពាន់ និងបីរយកៅសិបប្រាំដុល្លារអាមេរិក) និងជំនួយឥតសំណងរបស់រដ្ឋាភិបាលវៀតណាមចំនួន៣លានដុល្លារអាមេរិក(បីលានដុល្លារអាមេរិក) សម្រាប់ការសាងសង់មជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀននៅខេត្តព្រះសីហនុ ។ ជាមួយគ្នានេះ កាលពីក្នុងអំឡុងឆ្នាំ២០១៧ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ក៏បានផ្តល់ជំនួយក្នុងទឹកប្រាក់ចំនួន **១.១៥៥.៣៦១** ដុល្លារអាមេរិកសម្រាប់ការសាងសង់មជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀនផងដែរ មូលនិធិខាងលើត្រូវបានប្រើប្រាស់សម្រាប់ ៖

- ការកសាងមជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀន នៅភូមិឫទ្ធី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ
- ការផ្តល់ការលើកសរសើរដល់មន្ត្រីអនុវត្តច្បាប់ និងការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀន ។

**ជាមួយគ្នានេះ ក្រុមការងាររបស់ក្រសួងយុត្តិធម៌ និងគណៈកម្មការ ការតាមដាន ការប្រមូល ការគ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន** បានបន្តចុះតាមសាលាដំបូងរាជធានី ខេត្ត ដើម្បីពិនិត្យ និងប្រមូលមធ្យោបាយពាក់ព័ន្ធនឹងវត្ថុតាងបទល្មើសគ្រឿងញៀន ដែលត្រូវរឹបអូសជាសម្បត្តិរដ្ឋតាមសាលក្រមស្ថាពរ ដើម្បីវាយតម្លៃប្រកាសលក់ឡាយឡុង រួមមាន **ម៉ូតូ ២៩៥ គ្រឿង និងរថយន្ត០១គ្រឿង**(បាត់បង់គុណភាព) និងគិតជាតម្លៃប៉ាន់ស្មានប្រមាណជា **២៦.៩៧៥ ដុល្លារអាមេរិក (មានទិន្នន័យលម្អិតនៅក្នុងតារាងឧបសម្ព័ន្ធ)**។ ព្រមទាំងបាន និងកំពុងអនុវត្តនីតិវិធីបន្តក្នុងការដាក់លក់ឡាយឡុងដី០២កន្លែងនៅខេត្តត្បូងឃ្មុំ និងខេត្តកំពង់ចាម ។

**អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន** ក៏បានបន្តជម្រុញឲ្យក្រសួងយុត្តិធម៌ អន្តរាគមន៍ដល់ស្ថាប័នអយ្យការ និងតុលាការគ្រប់ជាន់ថ្នាក់ ឲ្យខិតខំប្រមូល គ្រប់គ្រងទ្រព្យសម្បត្តិ មធ្យោបាយ និងសម្ភារដែលជាកម្មវត្ថុនៃការចាប់យក និងរឹបអូសក្នុងបទល្មើសគ្រឿងញៀន ដើម្បីប្រគល់ជូនគណៈកម្មការ ការតាមដាន ការប្រមូល ការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀនឲ្យបានទាន់ពេលវេលា និងឈានទៅចាត់ចែងមូលនិធិជាតិខាងលើឲ្យមានប្រសិទ្ធភាពខ្ពស់ ។

## III. ការសន្និដ្ឋាន និងវាយតម្លៃ

### ១. ការអប់រំផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន ៖

**ចំណុចខ្លាំង ៖**

– គណៈកម្មការទទួលបន្ទុកអប់រំផ្សព្វផ្សាយនៃយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ បានរៀបចំឲ្យមានផែនការសកម្មភាពជាក់លាក់ និងមានលក្ខណៈពហុវិស័យ សម្រាប់ការបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀនប្រកបដោយគុណភាពទៅក្នុងគ្រប់វេទិកា និងព្រឹត្តការណ៍ផ្សេងៗក្នុងភូមិសាស្ត្រនៃដែនសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត ដើម្បីធានាបាននូវការយកចិត្តទុកដាក់អនុវត្តយ៉ាងសកម្ម និងប្រកបដោយការទទួលខុសត្រូវខ្ពស់ ស្របតាមស្មារតីនៃផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៥ ។

– ទទួលបានការចូលរួម និងគាំទ្រពីគ្រប់មជ្ឈដ្ឋានសង្គម ពិសេសពីស្ថាប័នជាតិសំខាន់ៗ ដូចជា ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល កាកបាទក្រហមកម្ពុជា ក៏ដូចជាការចូលរួម និងគាំទ្រពីវិស័យឯកជន វិស័យសាសនា មន្ត្រីរាជការស៊ីវិល អាជ្ញាធរគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ លោកគ្រូ-អ្នកគ្រូ និស្សិត សិស្សានុសិស្ស ប្រព័ន្ធផ្សព្វផ្សាយ វិទ្យុ ទូរទស្សន៍ បណ្តាញទំនាក់ទំនងសង្គម រួមផ្សំជាមួយនឹងការចូលរួមគាំទ្រកាន់តែសកម្ម និងផុលផុសពីសំណាក់ប្រជាពលរដ្ឋ ពិសេសនៅក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ សំដៅកាត់បន្ថយបទល្មើសគ្រឿងញៀន និងការពារបានសុខុមាលភាពសង្គមទាំងមូល ។

**ចំណុចខ្វះខាត ៖**

– ក្រុមគោលដៅដែលប្រឈមខ្ពស់នឹងគ្រោះថ្នាក់ដែលបណ្តាលមកពីគ្រឿងញៀន នៅតែជាក្រុមគោលដៅដែលទទួលបានសារអប់រំផ្សព្វផ្សាយតិចជាងគេ ។ **ក្រុមជនបង្គោល** សម្រាប់ការងារអប់រំផ្សព្វផ្សាយបន្ត ពិសេសសម្រាប់ក្រុមគោលដៅដែលប្រឈមខ្ពស់ខាងលើ នៅមិនទាន់បានធ្វើការបណ្តុះបណ្តាល និងចាត់តាំងចងក្រងឲ្យបានគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងឆ្លើយតបបានទៅគ្រប់ស្ថានភាពជាក់ស្តែងនៅឡើយ

– រដ្ឋបាលឃុំ-សង្កាត់ ក៏ដូចជាបណ្តាអង្គភាពពាក់ព័ន្ធនៅក្នុងមូលដ្ឋាន នៅតែមិនទាន់ទទួលខុសត្រូវដើរតួជាកម្លាំងជួរមុខ ម្ចាស់ការក្នុងការបង្ការទប់ស្កាត់ និងដោះស្រាយរាល់បញ្ហាកើតមានឡើងបណ្តាលមកពីគ្រឿងញៀន នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ភាគច្រើនពឹងផ្អែកតែទៅលើកិច្ចអន្តរាគមន៍ពីស្ថាប័នថ្នាក់លើ ។

### ២. ការកាត់បន្ថយគ្រោះថ្នាក់បណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន ៖

**ចំណុចខ្លាំង ៖**

– គណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន បានពង្រឹងនិងពង្រីកការងារព្យាបាល និងលើកកម្ពស់សមត្ថភាពមន្ត្រីរបស់ខ្លួនពីថ្នាក់ជាតិរហូតដល់ថ្នាក់មូលដ្ឋាន

– ការដាក់ឲ្យដំណើរការមជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀន នៅខេត្តព្រះសីហនុ

– ការកើនឡើងនូវការយល់ដឹង និងភ្ញាក់រលឹករបស់ប្រជាពលរដ្ឋ ក្នុងការបញ្ជូនកូនចៅដែលប្រើប្រាស់ ឬញៀនគ្រឿងញៀនឲ្យទៅទទួលយកសេវាព្យាបាល និងស្តារនីតិសម្បទា ។

**ចំណុចខ្វះខាត ៖**

– អ្នកញៀនគ្រឿងញៀនមួយចំនួន នៅមិនទាន់ភ្ញាក់រលឹកស្ម័គ្រចិត្តទៅទទួលសេវាព្យាបាល និងស្តារនីតិសម្បទា ដែលបញ្ហានេះអាចបណ្តាលមកពីការខ្មាស់អៀន និងខ្លាចការរើសអើង ឬការមិនយល់ដឹងច្បាស់លាស់ពីកម្មវិធីផ្តល់សេវាព្យាបាល និងស្តារនីតិសម្បទា

– ការផ្សព្វផ្សាយអំពីទីតាំងមូលដ្ឋានសុខាភិបាលសាធារណៈ ដែលបម្រើសេវាព្យាបាលជំងឺផ្លូវចិត្ត និងភាពញៀនគ្រឿងញៀន នៅពុំទាន់បានទូលំទូលាយទៅក្នុងស្រទាប់មហាជន ។

**៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តច្បាប់ ៖**

**ចំណុចខ្លាំង ៖**

– គណៈកម្មការបង្ការ ទប់ស្កាត់ និងបង្ក្រាបគ្រឿងញៀនខុសច្បាប់តាមច្រក នៃយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ បានចង្អុលដឹកនាំដល់អនុគណៈកម្មការចំនួន៣ គឺ ១-ទទួលបន្ទុកទប់ស្កាត់ និងបង្ក្រាបគ្រឿងញៀនតាមច្រកព្រំដែនកម្ពុជា-ឡាវ ២-ទទួលបន្ទុកទប់ស្កាត់ និងបង្ក្រាបគ្រឿងញៀនតាមច្រកអាកាសយានដ្ឋាន កំពង់ផែ និងច្រកទ្វារព្រំដែនអន្តរជាតិ និងច្រកទ្វារព្រំដែនទ្វេភាគី និង៣-ទទួលបន្ទុកទប់ស្កាត់ និងបង្ក្រាបគ្រឿងញៀនតាមបញ្ញើប្រៃសណីយ៍។ ព្រមជាមួយនោះ មន្ត្រីអនុវត្តច្បាប់ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិទទួលបាននូវការគាំទ្រជាថវិកាផ្តល់រង្វាន់ និងការសរសើរលើកទឹកចិត្តតាមគ្រប់រូបភាព ពីរាជរដ្ឋាភិបាល

– ការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់របស់រាជរដ្ឋាភិបាល បានជះឥទ្ធិពលជាវិជ្ជមានធ្វើឲ្យបទល្មើសទូទៅមានការថយចុះ ជាពិសេសបទល្មើសព្រហ្មទណ្ឌមានការថយចុះគួរកត់សម្គាល់

– ការបណ្តុះបណ្តាលជំនាញ គួបផ្សំនឹងការអនុវត្តជាក់ស្តែង រួមជាមួយការប្រើប្រាស់កម្លាំងសរុប ធ្វើឲ្យការស្រាវជ្រាវស៊ើបអង្កេតបទល្មើសកាន់តែមានប្រសិទ្ធភាព ។ ជាមួយគ្នានេះ តាមរយៈកិច្ចសហការផ្តល់ព័ត៌មានរហ័សទៅវិញទៅមកជាមួយប្រទេសជិតខាង និងស្ថាប័នអន្តរជាតិបានល្អ ធ្វើឲ្យសមត្ថកិច្ចទប់ស្កាត់ និងបង្ក្រាបបទល្មើសបានច្រើនករណីធំៗ ។

**បញ្ហាប្រឈម ៖**

– ឧក្រិដ្ឋជនអន្តរជាតិ នៅតែព្យាយាមប៉ុនប៉ងប្រើប្រាស់កម្ពុជា ធ្វើជាប្រទេសផលិតកែច្នៃ និងឆ្លងកាត់គ្រឿងញៀនខុសច្បាប់តាមគ្រប់រូបភាព ទាំងផ្លូវគោក ផ្លូវទឹក ផ្លូវអាកាស និងបញ្ញើប្រៃសណីយ៍

– បណ្តាខេត្តជាប់ព្រំដែន ពិសេសនៅភាគឦសានប្រទេស នៅតែជាខេត្តដែលបន្តមានសកម្មភាពចរាចរឆ្លងកាត់គ្រឿងញៀនខុសច្បាប់ ទោះបីការបង្ក្រាបបានចំករណីធំៗ និងកាត់ផ្តាច់ខ្សែរយៈអង្គការចាត់តាំងរបស់ក្រុមឧក្រិដ្ឋជនជាច្រើនហើយក៏ដោយ ។

**ចំណុចខ្វះខាត ៖**

–ការជួញដូរ ការប្រើប្រាស់គ្រឿងញៀន នៅតែបន្តកើតមានឡើងនៅតាមទីតាំងមួយចំនួនដូចជា ផ្ទះសំណាក់ ផ្ទះជួល សេវាកម្មកម្សាន្ត និងតំបន់ស្នូគស្មាញមួយចំនួន ។ គោលដៅដែលកើតបទល្មើសគ្រឿងញៀន គឺជាគោលដៅដដែលៗ អាចបណ្តាលមកពីភាពមិនស្មោះត្រង់នឹងវិជ្ជាជីវៈរបស់មន្ត្រីអនុវត្តច្បាប់ តាមទិសស្លោកពាក្យ ១របាយការណ៍របស់**សម្តេចក្រឡាហោម ស ខេង** ដែលនាំឲ្យជះឥទ្ធិពលអាក្រក់ដល់ប្រសិទ្ធិភាពអនុវត្តច្បាប់

–វិធានការបង្កក រឹបអូស និងលក់ទ្រព្យដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន នៅតែមានភាពយឺតយ៉ាវ មិនឆ្លើយតបទៅនឹងសំណូមពររបស់មូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

**៤. ការត្រួតពិនិត្យសារជាតុគីមីផ្សំ ៖**

**ចំណុចខ្លាំង ៖**

ដោយមានកិច្ចសហការល្អជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ យើងគ្រប់គ្រងបានជាប់ជាប្រចាំនូវទិន្នន័យសារធាតុគីមីផ្សំដែលមានការអនុញ្ញាតឲ្យនាំចូល និងតាមរយៈការបណ្តុះបណ្តាលសមត្ថភាពមន្ត្រីអនុវត្តច្បាប់ យើងកាន់តែមានបទពិសោធន៍ក្នុងការបង្ការ ទប់ស្កាត់ការបង្វែរសារធាតុគីមីផ្សំ ពីជំនួញស្របច្បាប់យកទៅសំយោគផលិតជាគ្រឿងញៀនខុសច្បាប់ ។

**ចំណុចខ្វះខាត ៖**

–ការបណ្តុះបណ្តាលជំនាញត្រួតពិនិត្យសារធាតុគីមីផ្សំដល់សមត្ថកិច្ចពាក់ព័ន្ធ និងបុគ្គលិកក្រុមហ៊ុនឧស្សាហកម្មគីមី នៅមិនទាន់ធ្វើបានទូលំទូលាយនៅឡើយ

–ការរៀបចំឲ្យមានអ្នកជំនាញទទួលខុសត្រូវ និងការធ្វើសន្និធិសារធាតុគីមីផ្សំ នៅតាមក្រុមហ៊ុន រោងចក្រ សហគ្រាស នៅមិនទាន់បានច្បាស់លាស់ គ្រប់ជ្រុងជ្រោយ និងមានវិធីសាស្ត្រសមស្រប ។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន ៖**

**ចំណុចខ្លាំង ៖**

កម្ពុជាបានចូលរួមយ៉ាងសកម្មក្នុងយន្តការនៃកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ជាមួយបណ្តាប្រទេសជាប់ព្រំដែន តាមរយៈការអនុវត្តតាមកំណត់ហេតុកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី ផែនការសកម្មភាពក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការទ្វេភាគី ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលក្នុងនោះ មានសកម្មភាពមួយចំនួនត្រូវបានកំណត់ជាអាទិភាព ៖

– ការផ្លាស់ប្តូរព័ត៌មានគ្នាទៅវិញទៅមកទាក់ទងនឹងបទល្មើសគ្រឿងញៀន ក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការត្រីភាគីនិងទ្វេភាគី បានធ្វើឡើងយ៉ាងសកម្មនិងផុលផុស ដើម្បីឈានទៅទប់ស្កាត់ និងបង្ក្រាបទាន់ពេលនូវករណីជួញដូរគ្រឿងញៀនឆ្លងកាត់ព្រំដែន

– ការឯកភាពគ្នារវាងកម្ពុជា និងភាគីឡាវ ថៃ និងវៀតណាម ដើម្បីរៀបចំបង្កើត" ភូមិ-ឃុំ/សង្កាត់ សគ្មានគ្រឿងញៀន" នៅតំបន់ព្រំដែនកម្ពុជា-ឡាវ កម្ពុជា-ថៃ និងកម្ពុជា -វៀតណាម

– ការយកចិត្តទុកដាក់ពង្រឹង និងពង្រីកការិយាល័យទំនាក់ទំនងព្រំដែន( BLO) ជាមួយប្រទេសជាប់ព្រំដែន ។

**ចំណុចខ្វះខាត៖**

ទោះបីជាយើងបានសហការជាមួយប្រទេសជិតខាងទទួលបានលទ្ធផលជាច្រើនក៏ពិតមែន ប៉ុន្តែការជួញដូរគ្រឿងញៀនឆ្លងកាត់ព្រំដែនប្រទេសកម្ពុជា ទៅកាន់ទីផ្សារគ្រឿងញៀនខុសច្បាប់ក្នុងតំបន់ និងពិភពលោកនៅតែបន្តកើតមាន ។

**៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា**

**ចំណុចខ្លាំង ៖**

កម្ពុជាបានប្តេជ្ញាចិត្តខ្ពស់ក្នុងការចូលរួមជាមួយសហគមន៍អន្តរជាតិ ក្នុងការតស៊ូប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន តាមរយៈការគាំទ្រ និងចូលរួមអនុវត្តផែនការសកម្មភាព ក្នុងក្របខ័ណ្ឌអាស៊ាន មហាអនុតំបន់ទន្លេមេគង្គ ក្រោមការសម្របសម្រួលរបស់អង្គការUNODC និងការអនុវត្តផែនការសហប្រតិបត្តិការជាមួយបណ្តាប្រទេសនានានៅក្នុងតំបន់ និងពិភពលោក រួមទាំងជាមួយដៃគូអង្គការ និងភ្នាក់ងារអន្តរជាតិនានា ។

**ចំណុចខ្វះខាត៖**

ទោះបីយើងបានធ្វើសកម្មភាពលេចធ្លោដូចបានជម្រាបជូនខាងលើក្តី តែការជួយគាំទ្រជាថវិកា មធ្យោបាយ និងសម្ភារពីបណ្តាប្រទេសផ្តល់ជំនួយ ក៏ដូចជាដៃគូអភិវឌ្ឍន៍នានាលើសកម្មភាពត្រួតពិនិត្យគ្រឿងញៀន បានកាត់បន្ថយមកនៅក្នុងកម្រិតតិចតួចបំផុត ដែលទាំងអស់នេះបានជះឥទ្ធិពលមិនល្អ និងធ្វើឲ្យសកម្មភាពត្រួតពិនិត្យ

គ្រឿងញៀនមានភាពអសកម្មដោយអន្លើ ទាំងនៅកម្ពុជា និងក្នុងតំបន់ទាំងមូល ។ **ជាមួយគ្នានេះ យើងនៅតែពិនិត្យឃើញថា ការចូលរួម សហការសម្របសម្រួលអនុវត្តក្នុងភាពជាដៃគូនៃកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន តាមរយៈជំនួបពិភាក្សាការងារចូលរួមកិច្ចប្រជុំ វគ្គបណ្តុះបណ្តាល ទស្សនកិច្ចសិក្សា បានជាច្រើនក៏ដោយ ប៉ុន្តែប្រសិទ្ធភាពឆ្លើយតបទទួលបានជាលទ្ធផលនៅតិចតួចបំផុត ។**

**៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ៖**

**ចំណុចខ្លាំង ៖**

ការបន្តដាក់ចេញនូវផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៥ បានឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការបន្តពុះពារលុបបំបាត់គ្រឿងញៀននៅកម្ពុជា ដោយទទួលបាននូវការគាំទ្រ និងវាយតម្លៃខ្ពស់ពីគ្រប់មជ្ឈដ្ឋានជាតិ និងអន្តរជាតិ ។

**ចំណុចខ្វះខាត ៖**

ការជំរុញលើកទឹកចិត្តលើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ស្របតាមគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព គោលនយោបាយភូមិ-ឃុំ/សង្កាត់ ស គ្មានគ្រឿងញៀន និងបទបញ្ជាលេខ០១ ស្តីពីការពង្រឹងវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀនរបស់រាជរដ្ឋាភិបាល នៅមានកម្រិត ការរៀបចំច្បាប់ ស្តីពីវិសោធន៍កម្មច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន កំពុងស្ថិតក្នុងនីតិវិធីក្រសួងជំនាញ ។

## IV. ទិសដៅការងារត្រីមាសទី២ ឆ្នាំ២០២០ (ទិសដៅផ្សេងទៀតមាននៅក្នុងឯកសារឧបសម្ព័ន្ធ)

ផ្អែកតាមការសន្និដ្ឋាន និងវាយតម្លៃលើលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនត្រីមាសទី១ ក្នុងការអនុវត្តផែនការជាតិ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៥ ក៏ដូចជា ដើម្បីធានាបាននូវនិរន្តរភាពក្នុងសកម្មភាពជាប្រចាំលើការងារអប់រំផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងជាសាធារណៈពីគ្រោះថ្នាក់នៃគ្រឿងញៀន ។ ការបន្តជំរុញសកម្មភាពការងាររបស់គណៈកម្មាធិការទទួលបន្ទុកការងារព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន។ការបន្តពង្រឹងសមត្ថភាព ឆន្ទៈ គុណធម៌ស្មោះត្រង់នឹងវិជ្ជាជីវៈរបស់មន្ត្រីអនុវត្តច្បាប់ តាមទិសស្លោកកុំ៣ ១រាយការណ៍របស់ **សម្តេចក្រឡាហោម ស ខេង** ។ បន្តពង្រឹងសមត្ថភាពត្រួតពិនិត្យ និងគ្រប់គ្រងសារធាតុគីមីផ្សំ។ ការបន្តកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែនប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា ក៏ដូចជាការរៀបចំលិខិតបទដ្ឋានគតិយុត្ត គោលការណ៍ណែនាំ គោលនយោបាយ និងច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ល។ **អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រួមជាមួយក្រសួង ស្ថាប័នជាសមាជិក គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត នឹងដាក់ចេញនូវទិសដៅការងារត្រួតពិនិត្យគ្រឿងញៀនសម្រាប់អនុវត្តក្នុងត្រីមាសទី២ ឆ្នាំ២០២០ ដូចខាងក្រោម ៖**

**១. ការអប់រំផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន ៖**

**១.១.** បន្តការចុះចែកខិតប័ណ្ណ កូនសៀវភៅអប់រំ និងការបិទផ្ទាំងរូបភាព ពិសេសការបោះពុម្ព និងផ្សព្វផ្សាយទិសស្លោករបស់**សម្តេចក្រឡាហោម ស ខេង** ៣កុំ ១រាយការណ៍ នៅតាមក្រសួង ស្ថាប័ន អង្គភាព គ្រឹះស្ថានសិក្សា រោងចក្រ សហគ្រាស ការដ្ឋានសំណង់ កសិដ្ឋាន លំនៅដ្ឋានកម្មករ និងលើយានយន្ត។ល។

**១.២.** បន្តការងារអប់រំផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងជាសាធារណៈពីគ្រោះថ្នាក់នៃគ្រឿងញៀនដល់ក្រុមគោលដៅប្រឈម និងងាយប្រឈមនឹងគ្រោះថ្នាក់ ដូចជា ក្រុមយុវវ័យ ពលករចល័ត ពលករចំណាកស្រុក កម្មករសំណង់ កម្មកររោងចក្រ កម្មករក្រៅប្រព័ន្ធ អ្នកបើកបររថយន្តដឹកទំនិញ និងដឹកអ្នកដំណើរ អ្នកបំរើការងារនៅតាមក្លឹបកម្សាន្ត និងទីតាំងសប្បាយដ្ឋាននានា ក៏ដូចជាបន្តជំរុញការបណ្តុះបណ្តាល ចាត់តាំងចងក្រងក្រុមជនបង្គោល និងការបណ្តុះបណ្តាលអប់រំផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀនដល់មន្ត្រីក្រោមឱវាទ នៅផ្ទៃក្នុងក្រសួង ស្ថាប័ន អង្គភាព ។

**១.៣.** បន្តបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀន នៅក្នុងកម្មវិធីប្រគុំតន្ត្រី ការផ្សព្វផ្សាយពាណិជ្ជកម្ម កម្មវិធីបុណ្យជាតិ-អន្តជាតិធំៗ។ល។ នៅគ្រប់វេទិកា និងព្រឹត្តការណ៍សង្គមផ្សេងៗក្នុងភូមិសាស្ត្រនៃដែនសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន និងរាជធានី ខេត្ត ។

**១.៤.** បន្តរៀបចំឲ្យមានខ្លឹមសារហាមឃាត់ការជួញដូរនិងប្រើប្រាស់គ្រឿងញៀននៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់សណ្ឋាគារ ផ្ទះសំណាក់។ល។ និងជំរុញការផ្សព្វផ្សាយបទបញ្ជាផ្ទៃក្នុង ក៏ដូចជាការផលិតខិតបណ្ណអប់រំផ្សព្វ-ផ្សាយពីគ្រោះថ្នាក់នៃគ្រឿងញៀន ដើម្បីបិទនៅតាមមូលដ្ឋានអាជីវកម្ម សេវាកម្ម និងតាមគោលដៅទេសចរណ៍ ។ ជាមួយគ្នានេះ បន្តជំរុញឲ្យដាក់សារអប់រំអំពីគ្រោះថ្នាក់នៃគ្រឿងញៀននៅគ្រប់ផលិតផល ។

**១.៥.** បន្តបើកវគ្គបណ្តុះបណ្តាលចំណេះដឹងជាមូលដ្ឋានអំពីគ្រឿងញៀន និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនដល់ថ្នាក់មូលដ្ឋាន ឃុំ សង្កាត់ ។

**១.៦.** សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីរៀបចំបណ្ណាល័យឌីជីថលអប់រំផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀននៅបណ្ណាល័យសម្តេចតេជោ ហ៊ុន សែន០១កន្លែង និងនៅសាលាធនធានចំនួន០៩កន្លែង ។

**១.៧.** គាំទ្រដល់ក្រសួងអប់រំ យុវជន និងកីឡា ផលិតឧបទ្ទេសសិក្សា ដូចជា សៀវភៅសិក្សាគោល ស្តីពីគ្រឿងញៀន និងសុវត្ថិភាពនៃការអភិវឌ្ឍ សៀវភៅ ស្តីពីវិធីសាស្ត្រនៃការបង្រៀន និងការបណ្តុះបណ្តាលគ្រូបង្រៀននៅតាមគ្រឹះស្ថានគរុកោសល្យខេត្ត និងវិទ្យាស្ថានបណ្តុះបណ្តាលគ្រូ ។

**១.៨.** បន្តអភិវឌ្ឍខ្លឹមសារមេរៀន ស្តីពីការបង្ការបញ្ហាគ្រឿងញៀននិងវិធីបង្រៀនសម្រាប់ដាក់ចូលទៅក្នុងសៀវភៅសិក្សាគោល និងមុខវិជ្ជាអប់រំសុខភាព សម្រាប់ថ្នាក់អប់រំមូលដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

**១.៩.** បន្តបញ្ជូនសារអប់រំផ្សព្វផ្សាយតាមទូរស័ព្ទចល័ត តាមគេហទំព័ររបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងតាមរយៈសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ ។

**១.១០.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. នឹងដើរតួជាអ្នកសម្របសម្រួល ដើម្បីធានាថា ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត នឹងចាត់វិធានការអនុវត្តរាល់សកម្មភាពដូចមានពីចំណុច ១.១ ដល់ចំណុច ១.៩ ឱ្យកាន់តែសកម្មថែមទៀត ។

**២. ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន ៖**

**២.១.** រៀបចំគោលការណ៍គ្រឹះសម្រាប់ការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅក្នុងក្របខណ្ឌមជ្ឈមណ្ឌលជាតិដោយឡែក និងសម្រាប់មណ្ឌលបណ្តោះអាសន្ន មណ្ឌលឯកជនដោយឡែក ។

**២.២.** បន្តការរៀបចំឲ្យមានគណៈគ្រប់គ្រង កម្មវិធីការងារ និងបទដ្ឋានបច្ចេកទេសពាក់ព័ន្ធ សម្រាប់ដំណើរការមជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ ដល់អ្នកញៀនគ្រឿងញៀននៅខេត្តព្រះសីហនុ ។ បន្តសហការពិភាក្សាជាមួយក្រសួងមហាផ្ទៃ អំពីគម្រោងសាងសង់មណ្ឌលព្យាបាលអ្នកញៀនគ្រឿងញៀននៅខេត្តពោធិ៍សាត់ ។

**២.៣.** បន្តជំរុញការព្យាបាល និងស្តារនីតិសម្បាទាអ្នកញៀនគ្រឿងញៀន ដោយផ្អែកលើសហគមន៍តាមរយៈសេវាសុខភាពផ្លូវចិត្ត និងការបំពានគ្រឿងញៀនរបស់ក្រសួងសុខាភិបាល និងជម្រុញការរៀបចំតម្លើងបញ្ជីឈ្មោះឃុំ សង្កាត់គោលដៅចំនួនជាង៤៥០ ដែលបានបើកបម្រើសេវាខាងលើ ក៏ដូចជាបង្កើនការបណ្តុះបណ្តាល និងរៀបចំពេទ្យជំនាញព្យាបាលជំងឺផ្លូវចិត្ត និងភាពញៀនគ្រឿងញៀននៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ។

**៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តច្បាប់ ៖**

**៣.១.** បន្តពង្រឹងប្រសិទ្ធភាពអនុវត្តច្បាប់ ដើម្បីបំផ្លាញអង្គការចាត់តាំងឧក្រិដ្ឋជនគ្រឿងញៀន ដោយសហការយ៉ាងជិតស្និទ្ធជាមួយអន្តរជាតិ បណ្តាប្រទេសក្នុងតំបន់ អនុតំបន់ ប្រទេសជិតខាង ដើម្បីទប់ស្កាត់ការហូរចូលគ្រឿងញៀនគ្រប់ប្រភេទ ទាំងនៅតាមព្រលានយន្តហោះ នៅតាមបញ្ញើប្រៃសណីយ៍ ពិសេសនៅតំបន់ព្រំដែនកម្ពុជា-ឡាវ។បន្តស្រាវជ្រាវ និងបង្ក្រាបករណីផលិតកែច្នៃគ្រឿងញៀន ករណីដាំដុះរុក្ខជាតិញៀនកញ្ឆា ។ ពង្រឹង និងពង្រីកការិយាល័យទំនាក់ទំនងព្រំដែន(BLO)។ បន្តលើកកម្ពស់សមត្ថភាពជំនាញដល់មន្ត្រីអនុវត្តច្បាប់និងលើកកម្ពស់សមត្ថភាពមន្ទីរពិសោធន៍គ្រឿងញៀន ក៏ដូចជាការពង្រឹងវិធានការអនុវត្តច្បាប់ ដើម្បីគាំទ្រដល់កម្មវិធីកាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើបំពានគ្រឿងញៀន ។

**៣.២.** បន្តពង្រឹងសមត្ថភាព ឆន្ទៈ គុណធម៌ស្មោះត្រង់នឹងវិជ្ជាជីវៈរបស់មន្ត្រីអនុវត្តច្បាប់តាមទិសស្លោក កុំ៣ ១រាយការណ៍របស់ **សម្តេចក្រឡាហោម ស ខេង** គឺ ៖ ១-កុំឲ្យពាក់ព័ន្ធ ២-កុំអន្តរាគមន៍ ៣-កុំលើកលែង និងត្រូវរាយការណ៍គ្រប់ករណីបទល្មើសគ្រឿងញៀន ។

**៣.៣.** បន្តពង្រឹងកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន នៅតាមក្លឹបកម្សាន្ត និងទីតាំងសប្បាយដ្ឋានដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ។

**៣.៤.** ជំរុញ និងពន្លឿននីតិវិធីនៃចំណាត់ការរឿងក្តីចេញសេចក្តីសម្រេច ឬ សាលក្រមរឹបអូសទ្រព្យសម្បត្តិរបស់ជនល្មើសដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ។

**៣.៥.** ពន្លាតនីតិវិធីនៃការស្វែងរកទ្រព្យសម្បត្តិ និងផលដែលកើតចេញពីបទល្មើសគ្រឿងញៀនរបស់ជនល្មើស ដើម្បីបង្កកជាបណ្តោះអាសន្នតាមបញ្ញត្តិនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**៣.៦.** ជំរុញ និងពន្លឿននីតិវិធីនៃចំណាត់ការចំពោះសាលក្រម ដែលបានជំនុំជម្រះសម្រេចរឹបអូសទ្រព្យសម្បត្តិ ហើយនៅមិនទាន់ចេញជាស្ថាពរ ។

**៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ ៖**

**៤.១.** បន្តសម្របសម្រួល និងជម្រុញដល់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួងសុខាភិបាល រៀបចំវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលា សម្រាប់ម្ចាស់ និងបុគ្គលិកគ្រប់គ្រងក្រុមហ៊ុន រោងចក្រសហគ្រាស ដែលមានប្រតិបត្តិការពាក់ព័ន្ធនឹងសារធាតុគីមី ឲ្យមានការយល់ដឹងអំពីការគ្រប់គ្រងការប្រើប្រាស់ និងរក្សាទុក ពិសេសយល់ដឹងអំពីការបង្វែរសារធាតុគីមីផ្សំពីជំនួញស្របច្បាប់ យកទៅសំយោគផលិតគ្រឿងញៀនខុសច្បាប់ ។

**៤.២.** បន្តរៀបចំឲ្យមានអ្នកជំនាញទទួលខុសត្រូវច្បាស់លាស់ក្នុងការគ្រប់គ្រងសារធាតុគីមីផ្សំនៅតាមមូលដ្ឋានផលិតកម្មនានា និងឈានទៅធ្វើការបណ្តុះបណ្តាលពង្រឹងសមត្ថភាពអ្នកជំនាញទាំងនោះ ។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន ៖**

បន្តពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន តាមគ្រប់យន្តការ ទាំងទ្វេភាគី ត្រីភាគីពហុភាគី ដើម្បីទប់ស្កាត់ការហូរចូលគ្រឿងញៀននៅតាមព្រំដែន ដូចជាការពង្រឹងយន្តការ និងពង្រីកការិយាល័យទំនាក់ទំនងព្រំដែន(BLO) ពិសេសការកសាង**ភូមិ-ឃុំ/សង្កាត់ ស គ្មានគ្រឿងញៀន**នៅតាមបណ្តោយព្រំដែនដែលភាគីកម្ពុជា ឡាវ ថៃ និងវៀតណាម បានឯកភាពគ្នាកន្លងមក ។

**៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយបណ្តាប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា ៖**

**៦.១.** បន្តបង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសនានា ទាំងក្នុងពិភពលោក ក្នុងតំបន់ ដើម្បីស្វែងរកការគាំទ្រសម្រាប់សកម្មភាពត្រួតពិនិត្យគ្រឿងញៀន ពិសេសពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអង្គការដៃគូជាតិ អន្តរជាតិ ដើម្បីស្វែងរកមូលនិធិគាំទ្រលើការងារព្យាបាលអ្នកញៀនគ្រឿងញៀន ដោយផ្អែកលើសហគមន៍។

**៦.២.** បន្តជំរុញការអនុវត្តស្មារតីលទ្ធផលទស្សនកិច្ចការងាររបស់ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**នៅសាធារណរដ្ឋប្រជាមានិតចិន កាលពីចុងឆ្នាំ២០១៩ កន្លងទៅ ដែលភាគីអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន កម្ពុជា និងភាគីគណៈកម្មាធិការជាតិត្រួតពិនិត្យគ្រឿងញៀនចិន បានព្រមព្រៀងគ្នា ។

**៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ**

**៧.១.** បន្តជំរុញការរៀបចំបញ្ចូលគណៈកម្មការកសាងភូមិ-ឃុំ/សង្កាត់ ស គ្មានគ្រឿងញៀន ទៅក្នុងសមាសភាពគណៈកម្មការដឹកនាំ និងអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ជាយន្តការតែមួយ ។

**៧.២.** បន្តរៀបចំវគ្គបណ្តុះបណ្តាលចំណេះដឹងជាមូលដ្ឋានអំពីគ្រឿងញៀន និងច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដល់មូលដ្ឋានឃុំ សង្កាត់ ។ ជាមួយគ្នានេះ នឹងបន្តសហការជាមួយក្រសួងមហាផ្ទៃដើម្បីធ្វើការបណ្តុះបណ្តាលទាំងក្នុងក្របខណ្ឌគណៈកម្មការភូមិ ឃុំមានសុវត្ថិភាពផងដែរ ។

**៧.៣.** បន្តរៀបចំគោលនយោបាយជាតិ ស្តីពីការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

**៧.៤.** ជំរុញនីតិវិធីពិនិត្យសេចក្តីព្រាងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**៧.៥.** ជំរុញការងាររៀបចំសេចក្តីព្រាងគោលនយោបាយជាតិ និងគោលការណ៍ណែនាំសម្រាប់ការរៀបចំបង្កើតភូមិ-ឃុំ/សង្កាត់ ស គ្មានគ្រឿងញៀន។

**៧.៦.** បន្តអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៥ ។

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា** ដែលតែងតែផ្តល់នូវឱវាទប្រកបដោយព្រហ្មវិហារធម៌លើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ដែលបានដឹកនាំយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ចំនួន៥លើក និង៤ឆ្នាំជាប់គ្នា (២០១៧-២០២០) ទទួលបានជោគជ័យយ៉ាងធំធេងប្រកបដោយការទទួលខុសត្រូវ មានការគាំទ្រ និងវាយតម្លៃខ្ពស់ពីសាធារណមតិជាតិ អន្តរជាតិ ក៏ដូចជាប្រជាពលរដ្ឋទូទៅ ឈានឆ្ពោះទៅរកជោគជ័យក្នុងវិស័យប្រយុទ្ធប្រឆាំងគ្រឿងញៀននៅកម្ពុជា។

សូមថ្លែងអំណរគុណដល់គ្រប់ក្រសួង ស្ថាប័ន ព្រមទាំងមន្ត្រីរាជការក្រោមឱវាទ ទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ វិស័យសាសនា បុគ្គលពាក់ព័ន្ធ ក៏ដូចជាសមាគមសង្គ្រោះ និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដែលបានចូលរួមជាមួយរាជរដ្ឋាភិបាល ក្នុងការគាំទ្រការកសាងមជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀន នៅភូមិឫទ្ធី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ និងនៅកន្លែងផ្សេងៗទៀតក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូល ។ សូមអរគុណចំពោះដៃគូអភិវឌ្ឍន៍ជាតិ អន្តរជាតិ សង្គមស៊ីវិល ផ្នែកឯកជន សប្បុរសជន សិល្បករ និងជាប្រជាពលរដ្ឋ ដែលបានរួមចំណែកជាមួយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្នុងការធ្វើឲ្យបានសម្រេចលទ្ធផលជាផ្លែផ្កាដូចមានក្នុងរបាយការណ៍នេះ។

សំណូមពរ និងអំពាវនាវដល់ផ្នែកពាក់ព័ន្ធទាំងអស់ សូមបន្តចូលរួមចំណែកដល់ការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៥ និងទិសដៅការងាររបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនសម្រាប់ត្រីមាសទី២ឆ្នាំ២០២០ ដើម្បីនាំមកនូវលទ្ធផលកាន់តែល្អប្រសើរ ធានាបាននូវសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ថែរក្សាបាននូវសុខុមាលភាព និងការអភិវឌ្ឍសង្គម និងកសាងបាននូវធនធានមនុស្សប្រកបដោយសក្តានុពលភាពសម្រាប់ជាតិ។

ឧបនាយករដ្ឋមន្ត្រី
ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

នាយឧត្តមសេនីយ៍. កែ_គឹមយ៉ាន

**ចម្លងជូន** :
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
" ដើម្បីជូនជ្រាប "
-ក្រសួងសមាជិក អ.ជ.ប.គ.ញ.
-អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ.
-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី ខេត្ត
-នាយកដ្ឋានសរុប នៃទីស្តីការគណៈរដ្ឋមន្ត្រី
" ដើម្បីមុខការ "
-ឯកសារ-កាលប្បវត្តិ